- ការដកដង្ហើមមានការពិបាក។ ការទទួលខុសត្រូវនៃសម្លាចទ្រូងខ្សោយនៅពេលក្មេងៗដកដង្ហើម។ ឬក៏ដកដង្ហើមវែងៗ ឮសូរគ្រូកក្រាកៗ នៅពេលក្មេងដកដង្ហើមចូលក្នុងខ្លួន។
- ការក្អករ៉ាំរ៉ៃ ឬជាបញ្ហានៃផ្លូវដង្ហើមដែលបានចាប់ផ្ដើមច្រើនជាង៣០ថ្ងៃ(អាចជាទេព ឬ រោគហឺត)។
- មិនអាចញ៉ាំបាន ឬបំបៅដោះបាន។
- វាអាចធ្វើឱ្យឈឺ ប៉ុន្តែក៏វាអាចប្រសើរឡើងវិញក្នុងរយៈពេល ៣ថ្ងៃ។
- ហាក់ដូចជាមានការឈឺចាប់។
- វាអាចក្អួតចង្អោរកំឡុងពេលយូរ។
- អាចជាគ្រុនញាក់។
- ដេកស្ពូកស្ពឹង(មានការពិបាក)។
- វាអាចមានការយំ ឬ ខឹងនៅពេលដែលយើងលើកប៉ះចំករ.វាពីដំណេកទៅដាក់កន្លែងមួយផ្សេងទៀត(អាចជារោគ រលាកស្រោមខួរ)។
- ប្រសិនបើមិនស្រួលខ្លួនលើសពីរយៈពេល ៣ថ្ងៃចុងក្រោយ។
- ប្រសិនបើមិនស្រួលខ្លួន។
- ប្រសិនបើមិនស្រួលខ្លួន វាអាចនាំឱ្យក្មេងមានការញាក់ញ័រ ឬក៏ សង្ស័យថាមានជម្ងឺគ្រុនចាញ់ (សញ្ញាគ្រុនចាញ់ ឈឺក្បាល ឈឺសាច់ដុំ និង ខ្ទង់បែកញើស ដំណើរចង់ក្អួត និង ក្អួតចង្អោរ)
- ក្នុងនាមជាអាណាព្យាបាល ឬ ឪពុកម្ដាយ ត្រូវមើលការខុសត្រូវកូនឱ្យចៀសផុតពីជម្ងឺ។

## 33.រោគរបេង

រោគរបេង ឬ TB គឺជាជម្ងឺឆ្លងមួយដែលគំរាមកំហែងជីវិតមនុស្សសំខាន់ផងដែរ។ TB រីករាលដាលតាមរយៈ

ខ្យល់នៅពេលដែលមានមនុស្សក្អក (មនុស្សពេញវ័យ)។ (កុមារងាយស្រួលនឹងឆ្លងជាមួយនឹង TB ទោះបីជាយ៉ាងណាមនុស្សធំបានចម្លងទៅកុមារដោយការក្អក)។ វាងាយស្រួលរាលដាលទៅមនុស្សផ្សេងទៀតដែលរស់នៅក្នុងផ្ទះតែមួយ។

រោគសញ្ញាសាមញ្ញបំផុតគឺ TB គឺជាការក្អកដែលលើសពីមួយខែ។ ប្រសិនបើយើងមានក្អកច្រើនជាងមួយខែដូច្នេះហើយអ្នកទៅពិគ្រោះជាមួយលោកគ្រូពេទ្យ ឬ មណ្ឌលសុខភាពដែលនៅក្បែរផ្ទះរបស់អ្នក។ ការក្អកមានស្លេះចេញឈាមអាចផ្សេងពីនេះដែលក្អកយូរ មនុស្សពេញវ័យតែងតែមិនមានអារម្មណ៍ឈឺជាមួយ TB និងដូច្នេះហើយបានជាអ្នកទាំងនោះតែងតែពន្យាពេលសម្រាប់ការធ្វើតេស្តរករោគរបេង។ នេះគឺជាការគ្រោះថ្នាក់បំផុត ជាពិសេសទៅលើកុមារ ឬមនុស្សជំទង់ ដែលអាចងាយនឹងទទួលរង។

កុមារ និងមនុស្សវ័យជំទង់គឺឆាប់ឈឺទៅនឹង TB និងតែងតែឈឺដូចជាគ្រុនក្តៅ វងារញាក់ និងងងុយដេកស្រកទំងន់ និង ឈឺសន្លាក់ឆ្អឹង។

ដូច្នេះអ្វីដែលសំខាន់បំផុតនោះគឺការការពារយកមនុស្សដែលតែងតែក្អកទៅធ្វើតេស្តស៏ក្នុងកំឡុងពេលច្រើនជាងមួយខែ និងប្រសិនបើពិនិត្យទៅឃើញវិជ្ជមាន នោះព្យាបាលដើម្បីការងារជម្ងឺកុំអោយឆ្លងទៅមនុស្សក្មេង និងមនុស្សជំទង់។

វាក៏មានសារៈសំខាន់ផងដែរដែលមនុស្សមានជំងឺរបេង (TB) ទទួលថ្នាំព្យាបាលរោគរហូតដល់គ្រូពេទ្យនិយាយថា អ្នកមានរោគរបេងព្យាបាលជាសះស្បើយមួយរយភាគរយ។ ជំងឺរបេង (TB) ពិបាកព្យាបាលណាស់ និងអ្នកជំងឺត្រូវតែទទួលថ្នាំព្យាបាលយ៉ាងហោចណាស់ក៏ចាប់ពី ៦ ខែ ទៅ ១ ឆ្នាំ ឬលើសពីនេះ។ ភ្លាយមកវិញវានឹងវិលត្រឡប់មកអ្នកមានរោគរបេងសារជាថ្មី និងពិបាកព្យាបាល ឬមិនអាចព្យាបាលបានតែម្តង។

## 34. ក្រម៉ារ

ក្រម៉ារគឺបណ្តាលមកពីពពួកសត្វល្អិតដែលកាត់ខោអាវ តូចៗដែលរូងចូលស្បែក និងបណ្តាលឱ្យរោលរមាស់។ មនុស្ស ជំទង់តែងតែទទួលរោលរវាងម្រាមដៃទាំងពីរ ដូច្នេះហើយកុមារអាចទទួលរងពីពពួកសត្វល្អិតគ្រប់ទិកន្លែងទាំងអស់។ រមាស់តែងតែបង្កនៅពេលយប់ ព្រោះថាមានប្រតិកម្មដែលងាយឈឺចាប់។ អេះកន្លែងរមាស់អាចបណ្តាលឱ្យបង្កើតជាខ្ទុះ។

អ្នកគួរស្តាប់តាមការណែនាំរបស់គ្រូពេទ្យ ភាពរមាស់ត្រូវព្យាបាលដោយការលេបថ្នាំ។

ពូក និងសំលៀកបំពាក់ត្រូវផ្លមជូររយៈពេល ៥ ថ្ងៃបន្ទាប់ពីចាប់ផ្តើមប្រើប្រាស់ គួរតែបោកជំរះជាមួយទឹកក្តៅ។ គួរទុកដាច់ដោយឡែកពីគេរយៈពេល ៥ ថ្ងៃ។ សត្វល្អិតមិនអាចរស់ក្នុងរយៈពេល ៤ ថ្ងៃដោយគ្មានស្បែកមនុស្ស

ឡើយ ។

ខ្ទួចធ្មាដៃរនឹងកមរមាស់ គឺ បណ្តាលមកពីប្រតិកម្មងាយឈឺចាប់ដែលវាអាចបាត់ទៅវិញក្នុងរយៈពេលជាច្រើនសប្តាហ៏ ថ្វីបើការព្យាបាលជោគជ័យក៏ដោយ ។ ប្រសិនបើរមាស់ព្យាយាមគ្រប់គ្រងនៅពេលដេក អ្នកអាចស្នើរដល់ក្រុមគ្រូពេទ្យនូវថ្នាំការពាររមាស់ ។

## 35. សុខៈវិជ្ជា (វិជ្ជាសិក្សារអំពីសុខភាព)

បន្ថែមលើសពីនេះការលាងដៃ ងូតទឹក និងបោកគក់សំលៀកបំពាក់គឺជាការសំខាន់ ។

កុមារដែលងូតទឹកតាមទឹកទន្លេ ធ្វើឱ្យមានរូបភាពស្រស់ស្អាត តែអកុសល ទាំងនេះគឺជាការអនុវត្តន៏ដោយគ្រោះថ្នាក់ ។ លើកលែងតែអ្នកទាំងនោះហែលប្រច្រាសទឹក និងប្រើប្រាស់បង្គន់ត្រឹមត្រូវ និងមិនធ្វើឱ្យមានការកខ្វក់ទឹក អ្នកមិនគួរងូតទឹក ឬ បោកខោអាវនៅលើទន្លេ ឬ បឹងឡើយ ។ ជាអកុសល នៅគ្រប់ទឹកន្លែងទាំងអស់ ទឹកត្រូវបាននឹងកំពុងបង្កអោយមានការកខ្វក់ជាមួយបាក់តេរីដូចជា ជម្ងឺគ្រុនពោះវៀន ឬព្រូនដូចជា ស្គីសតូសូមីយ៉ាស៊ីស ។ អ្នកប្រើទឹកកខ្វក់ទាំងអស់នោះជាប្រចាំ វានឹងបណ្តាលឱ្យកើតជម្ងឺឆ្លង និងមិនស្រួលខ្លួន ។ ប្រសិនបើអ្នកមិនច្បាស់ថាជាទឹកស្អាតបរិសុទ្ធ អ្នកគួរតែដាំទឹកឱ្យពុះ ឬក៏ ចំហុយ (ចំហាយទឹកត្រជាក់ បន្ទាប់ពីដាំទឹករួច) ។ លាងធ្មេញរបស់អ្នកយ៉ាងហោចណាស់ពីរដងក្នុង១ថ្ងៃ និងកូតសំអាតធ្មេញនឹងខ្សែក្នុង១ថ្ងៃម្តងវាមានសារៈសំខាន់ដែលជាផ្នែកមួយនៃសុខៈវិជ្ជា (វិជ្ជាសិក្សារអំពីសុខភាព) ។ យើងនឹងនិយាយច្រើនអំពីសុខភាពមាត់ធ្មេញ ។

## 36. សុខភាពមាត់ធ្មេញសំរាប់មនុស្សពេញវ័យ

ធ្មេញពុកគឺជារឿងធម្មការដែលបណ្តាលឱ្យឈឺចុកចាប់ក្នុងមាត់ធ្មេញ ឬ ផ្ទៃមុខ និង មនុស្សពេញវ័យជាច្រើនបង្ហាញសញ្ញាពីមនុស្សឈឺអញ្ចាញធ្មេញ ដែលលទ្ធផលក្នុងការបាក់ (ឬ បាត់បង់ធ្មេញ) ។

➢ **តើយើងអាចនឹងធ្វើការថែរក្សាសុខភាពមាត់ធ្មេញឱ្យបានល្អយ៉ាងដូចម្តេច :**

-ជៀសវាងថ្នាំជក់ ។ ការជក់ដែលប្រើប្រាស់នៅក្នុងករណីផ្សេងៗ- បារីប្រើខ្សៀ និង (ស្លោះទឹកមាត់) ជក់បារីដែលបង្កើនការប្រថុយប្រថានទៅនឹងមហារីកមាត់ និង បំពង់ក ព្រមទាំងឆ្លងជំងឺផ្សិតមាត់ ។

-ស្រាមានកំរិត ។

-បរិភោគដោយឆ្លាតវ័យ ។ ជៀសវាងស្ករស ស្ករគ្រាប់ និង ម្សៅអាហារ ។ ផ្លែឈើដែលមានសរសៃច្រើន និងបន្លែគឺមានសារៈសំខាន់បំផុត ។

-ចូរបរិភោគទឹកដែលមានអនាម័យឱ្យបានច្រើន។ បើសិនជាអាច ចូរបរិភោគទឹកជាតិហ្លួយអូរីត និង ចូរប្រើប្រាស់ថ្នាំដុះធ្មេញ ដែលមានជាតិហ្លួយអូរីត។

-ប្រើប្រាស់សំរាប់ដុះសំអាតធ្មេញ និង ខ្សែកូតសំអាតធ្មេញ។ ដុះសំអាតធ្មេញ គួរតែធ្វើយ៉ាងហោចណាស់ ២ដងក្នុង១ថ្ងៃ (ជាធម្មតាបន្ទាប់ពីអាហារពេលព្រឹក និង មុនពេលចូលដំណេក) នឹងប្រើប្រាស់ខ្សែកូតសំអាតធ្មេញឱ្យបានយ៉ាងហោចណាស់ មួយដងក្នុង១ថ្ងៃ( មុនចូលដំណេក)។

-ចូរលាងសំអាតធ្មេញរបស់អ្នកជានិច្ច " ចូរខ្ពុរមាត់ " នៅចន្លោះធ្មេញជាមួយទឹកដែលមានអនាម័យបន្ទាប់ពិប្រើប្រាស់ច្រាស់ដុស ឬ ខ្សែកូតសំអាតធ្មេញ និង ក្រោយពីញុំាអាហារសំរនផងដែរ ឬ ដរាបណាដែលអ្នកមិនមានសមត្ថភាពប្រើប្រាស់ ឬ ខ្សែកូតសំអាតធ្មេញនោះ។

## 37. សុខភាពមាត់ធ្មេញសំរាប់ក្មេងៗ

ការមិនបានព្យាបាលធ្មេញពុកនឹងបណ្តាលឱ្យមានការឈឺចាប់ជាប្រចាំថ្ងៃបណ្តាលឱ្យ ឈឺចាប់យ៉ាងខ្លាំងមិនអាចបរិភោគអាហារបានស្រួល ឬ ទំពាបានល្អ នឹងមានការខ្មាសអៀនដែលខូនធ្មេញ និង មិនចង់រៀមសូត្រ។

- **តើឪពុកម្តាយអាចនឹងធ្វើអ្វីសំរាប់កូនរបស់ពួកគេ?**

-ចូរបំបៅដោះដល់ទារករបស់អ្នក និងមិនត្រូវប្រើដបទេ។ បើសិនជាអ្នកមិនបំបៅដោះ និងទារករបស់អ្នកត្រូវប្រើដប និងមិនត្រូវប្រើវានៅពេលម៉ោងគេងទេ។

-ចូរលើកទឹកចិត្តដល់កូនៗរបស់អ្នកឱ្យបរិភោគអាហារឱ្យទៀងទាត់ នឹង ជៀសវាងញ៉ាំកញ្ចប់អាហារសំរន។ សូដា និង ភេសជ្ជៈមានជាតិផ្អែម ស្ករគ្រាប់ និង ស្ករផ្សេងៗគឺអាចធ្វើឱ្យខូចធ្មេញតែម្តង។

-ចំពោះក្មេងៗត្រូវប្រើច្រាសតូចហើយទន់។ ការធ្វើឱ្យច្រាស់ដុសធ្មេញទន់អ្នកអាចដាក់ត្រាំនឹងទឹកក្តៅ។

-ប្រើប្រាស់ដុសធ្មេញដែលធ្វើនៅផ្ទះគឺមានប្រសិទ្ធិភាពផងដែរ។ ការទាំងអស់នេះអាចនឹងធ្វើជាមួយខ្មែងឈើតូចៗដែលបានសំរួចវាឱ្យតូចៗ ដើម្បីនឹងសំអាតកំទេចកំទីដែលនៅចន្លោះធ្មេញ និងខាំបន្តិចៗដើម្បីធ្វើឱ្យច្រាសដុសសំអាត។ បើមិនមានលទ្ធភាពទិញ និងមិនមានលក់ទេ ចូរប្រើអំបោះដេរ ឬ ខ្សែសន្ទូចអាចប្រើបាន។ បន្ទាប់មកចូរខ្ពុរមាត់នៅចន្លោះធ្មេញជាមួយទឹកអនាម័យល្អ។ ចូរចាប់ផ្តើមប្រើថ្នាំដុសធ្មេញដែលមានជាតិហ្លួយអ៊ុរីតនៅពេលកូនៗរបស់អ្នកមានអាយុប្រហែល២ឆ្នាំ។ បើសិនជាអ្នកមិនអាចលក់លែរកទិញថ្នាំដុសធ្មេញដែលមានជាតិហ្លួយអូរីតទេ ចូរគ្រាន់តែប្រើថ្នាំដុសធ្មេញជាមួយនឹងទឹកដែលមានអនាម័យល្អ ឬ មេប្រៃបន្តិច។ ការប្រើប្រាស់ច្រាស់តែមួយមុខនឹងជួយការពារធ្មេញប្រហោង និងជំងឺអញ្ចាញធ្មេញ។

-ចូរដុសធ្មេញកូនរបស់អ្នកពីរដងក្នុង១ថ្ងៃ រហូតដល់កូនរបស់អ្នកមានបទពិសោធន៏កាន់ច្រាស់ដុសធ្មេញដោយ

ខ្លួនឯង។ ជាញឹកញាប់ការនេះគឺធ្វើបន្ទាប់ពីអាហារពេលព្រឹក និងពួកគេគួតែដុះធ្មេញរបស់ពួកគេមុនពេលចូលដំណេកជានិច្ច។

-បន្ទាប់មកចូរលាងសំអាតច្រាសដុសធ្មេញដោយហ្មត់ចត់ជាមួយនឹងទឹកអនាម័យល្អ ដើម្បីយកចេញឱ្យអស់នូវថ្នាំដុសធ្មេញ និងកំទេចកំទី ហើយចូរដាក់វាហាលថ្ងៃឱ្យស្ងួត និងយកវាមកទុកនៅកន្លែងដែលមានទីតាំងត្រឹមត្រូវ។

## 38A. ការញុាំចំណីអាហារដែលត្រឹមត្រូវ

ការញុាំចំណីអាហារបានក្លាយជាកត្តារិះគន់ខ្លាំងនៅក្នុងល័ក្ខខ័ណ្ឌសុខភាព និងសុខុមាលភាពរបស់មនុស្សទូទាំងពិភពលោក។ ទាំងភាពស្គមស្គាំង និង ភាពហូបបរបូរ ញ៉ាំងឱ្យទិន្នន័យការស្លាប់ក្នុងមួយឆ្នាំៗច្រើនឥតគណនា។

ទោះបីជាយ៉ាងណាក៏ដោយ បច្ចុប្បន្នមានរោគឆ្លងពាសពេញពិភពលោកយើងនេះនៃជម្ងឺធាត់ដែលបណ្តាលមកពីការហូបច្រើនដែលហូបសុទ្ធតែអាហារមិនត្រឹមត្រូវ។ ភាពធាត់ និងជាការទំនាក់ទំនងនៃជម្ងឺទឹកនោមផ្អែម ក៏រិតសម្ពាធឈាមខ្ពស់ ជម្ងឺគាំងបេះដូង ជម្ងឺដាច់សរសៃរឈាមខួរក្បាល និង រោគមហារីក គឺជាចង្កោមនៃអ្នកសម្លាប់ធំបំផុតលើមនុស្សពេញវ័យទូទាំងពិភពលោក។ យើងនឹងរំឭកឡើងវិញដំបូងគេនូវជំងឺស្គមស្គាំង។

នៅប្រទេសកំពុងអភិវឌ្ឍន៍ ការស្រកទំងន់កំពុងបាននឹងកំពុងសម្លាប់កុមារ ជាពិសេសក្មេងអាយុក្រោម ៥ ឆ្នាំ។ កុមារតូចៗងាយរងគ្រោះថ្នាក់បំផុត។ នៅក្នុងលក្ខខ័ណ្ឌការចិញ្ចឹមដោយដោះម្តាយដល់កូនគឺធ្វើរហូតដល់អាយុ ៣ ឆ្នាំ ហើយយើងគួរតែប្រាកដថាកុមារក្រោមអាយុ ៥ ឆ្នាំ អាចទទួលនូវការអាហារូបត្ថម្ភពីគ្រួសារ។

សម្រាប់កុមារដែលលែងបៅដោះម្តាយ និងមនុស្សពេញវ័យ **ទឹកដោះគោ** គឺជាធនធានល្អបំផុតនៃ**ប្រូតេអ៊ីន និងកាល់ស្យូម** (ការពារជំងឺអូស្តេអូផូរ៉ូស៊ីស-ជម្ងឺខ្សោយឆ្អឹង)។ ទោះបីជាយ៉ាងណាក៏ដោយអ្នកគួរតែប្រាកដថា ទឹកដោះគោ ដែល**កំដៅរម្ងាប់មេរោគ** (ឧទាហរណ៍ កំដៅ ៦០ អង្សាសេ ក្នុងរយៈពេល ៣០នាទី — កំដៅគឺមានសារៈសំខាន់ដើម្បីការពារជម្ងឺដូចជា ប្រ៊ូសែឡូស៊ីស និង TB ជំងឺសត្វគោ ) ឬ ប្រើម្សៅទឹកដោះគោដោយឆុងទឹកក្តៅ។ សម្រាប់មនុស្សជំទង់ និងមនុស្សពេញវ័យដែលលើសទំងន់ខ្វះ ឬ ខ្វះជាតិខ្លាញ់ គួរតែប្រើ។

**កង្វះខាតជាតិដែក វីតាមីន អា និង ជាតិដែក** គឺជារឿងពិសេសមួយ និងការបរិច្ចាកចំពោះអ្នកស្លាប់។ អាហារដែល សំបូរជាតិដែកមាន :ថ្លើម ខ្ទងគ្រែង គ្រាប់ធុញ្ញជាតិដែលសំបូរជាតិដែក ស្រាបៀរ ស្ពៃ ទំពាំងបាយជូរស្ងួត។

អាហារដែលមាន**វីតាមីន A** ខ្ពស់ រួមមាន : ម្សៅទឹកដោះគោ និងទឹកដោះគោ ស៊ុត ថ្លើម និងប្រេងខ្លាញ់ត្រីបន្លែពណ៌ បៃតង ផ្លែឈើ និងបន្លែពណ៌លឿង។

អាហារដែលមានជាតិដែកខ្ពស់ រួមមាន : ក្តាម ថ្លើម សាច់គោ សាច់ជ្រូក បសុបក្សី គ្រាប់ធញ្ញជាតិសំប៉ែត។ សណ្តែក និងល្ងស្ងួត ទឹកដោះគោ និងប្រូម៉ា។

- **ការញ៉ាំអាហារច្រើនមុខ :**

ដើម្បីទទួលបាននូវ កម្លាំង ប្រូតេអ៊ីន វីតាមីន សារជាតិខនិជ និងសរសៃ (សាច់ដុំ) ដែល ជាតំរូវការសម្រាប់ឱ្យមានសុខភាពល្អ។ ជួនកាលវាអាចពិបាកញ៉ាំពីក្រុមអាហារនីមួយៗក្នុងមួយថ្ងៃម្តងៗ។

ប៉ុន្តែដោយការប្រតិបត្តិដូចជាការដើរទិញទឹកដោះគោក្មេង ជំនួសអោយសូដា ហើយយើងនឹងជួយដល់ក្មេងៗឱ្យមានសុខភាពល្អ។ កុមារកុំញ៉ាំអាហារដែលមានជាតិផ្អែមខ្លាំង ឬ ក៏ផឹកកាហ្វេ។ បង្អែមជាបញ្ហាធម្មតាមួយដែលបណ្តាលឱ្យមានការពុកធ្មេញដែលធ្វើឱ្យមានឈឺចុកចាប់។

**កុំផឹកសុរា.**ស្រាគឺមានគ្រោះថ្នាក់ខ្លាំងបំផុត និងធ្វើឱ្យញៀន។ គារប្រថុយប្រថាននូវការសេពសុរាកើនឡើងនៅពេលចាប់ផ្តើមផឹកស្រានៅវ័យក្មេងជាការប្រព្រឹត្តខុសទាំងស្រុង។ ការសេពអាកុលហួសកំណត់ គឺជាការធ្វើវិភេទសុភវិនិច្ឆ័យ និងអាចនាំមកនូវភាពមិនឯករាជ្យ និងបញ្ហាខាងផ្នែកសុខភាព។

**ផឹកស្រាច្រើនអាចបង្កឱ្យអ្នកបើកម៉ូតូមានគ្រោះថ្នាក់ ឬ រងគ្រោះផ្សេងទៀត សម្ពាធឈាមខ្ពស់ ដាច់សរសៃឈាមក្នុងខួរក្បាល អំពើហឹង្សា ការធ្វើអត្តឃាដ និងជំងឺមហារីកធ្ងន់ធ្ងរ រួមទាំងមហារីកដោះ។ គារបរិភោគស្រាកំឡុងពេលមានផ្ទៃពោះ (មានគ៌រ) គឺមានគ្រោះថ្នាក់កើនឡើងដល់ការបង្កកំណើត។ ស្រាតែងតែបង្កបញ្ហាដល់សង្គម និងចិត្តវិជ្ជា រោគក្រិនថ្លើម រលាកលំពែង និងបំផ្លាញការចងចាំរបស់ខួរក្បាល និងជម្ងឺបេះដូង។**

## 38B. ការញ៉ាំចំណីអាហារដែលត្រឹមត្រូវ (ត)

**អាហារពីរ៉ាមីត**នីមួយៗ បាននឹងកំពុងអភិវឌ្ឍន៍ដើម្បីបង្ហាញទំនាក់ទំនងរវាងតម្លៃ និងប្រភេទរបស់អាហារដែលត្រូវបានគេផ្តល់ជាអនុសាសន៍។ ភាពប្រែប្រួលទាំងនេះអាស្រ័យលើវប្បធម៌ និងភាពប្រើប្រាស់ឱ្យជាប្រយោជន៍នៃអាហារជាក់លាក់ណាមួយ ទោះបីជាយ៉ាងណា គោលការណ៍មូលដ្ឋានគឺដូចគ្នា។ ជាទូទៅ **របបអាហារសុខភាព** គឺមានដូចជា :

-សង្កត់ធ្ងន់លើបន្លែ ផ្លែឈើ និង គ្រាប់ធុញ្ញជាតិទាំងអស់

-រួមទាំងទឹកដោះគោ និងផលិតកម្មទឹកដោះគោ

-រួមទាំងសណ្តែក ទឹកដូង ស៊ុត ត្រី បសុបក្សី (មាន់ ទា ក្ងាន ។ល។) ឬ សាច់គ្មានខ្លាញ់ និង

-គឺសាច់ដែលមានខ្លាញ់គីរិតទាប ទ្រែទហ្វែត ខ្លាញ់ក្នុងប្រមាត់ អំបិល(សូដ្យូម) និងស្ករ។

**ជ្រើសរើសរបបអាហារជាមួយនឹងបន្លែ ផលិតកម្មគ្រាប់ធញ្ញជាតិ និងផ្លែឈើ** ដែលផ្តល់វីតាមីន សារជាតិខនិជ

ហ្វ្រាយ-ប័រ និងធាតុកាបូអ៊ីដ្រាត និងអាចជួយឱ្យយើងមានកំរិតធាត់ទាប។

**ការជ្រើសរើសរបបអាហារទាប ឬ ល្មមនៅក្នុងស្ករ**។ របបអាហារដែលមានជាតិស្ករច្រើនបានធ្វើឱ្យកើនឡើងច្រើននៃជាតិកាឡូរី និងសារជាតិធ្វើឱ្យធាត់ និងមានជម្ងឺពុកធ្មេញ។

**ការជ្រើសរើសរបបអាហារទាប ឬល្មមនៅក្នុងអំបិល (សូដ្យូម)**។ វាមានប្រយោជន៍ណាស់ ប្រសិនបើអ្នកមានសម្ពាធឈាមខ្ពស់។ គួរញ៉ាំ ឬ ជ្រើសរើសបន្លែ និងផ្លែឈើជាប្រចាំ។ ជំនួសអោយតារាងអំបិលប្រើជារុក្ខជាតិក្លិនក្រអូបប្រើជាគ្រឿងសម្ល (ឬថ្នាំ) កញ្ឆា និងអាហារសំដៅលើម្សៅម្ហូប។

**គុណប្រយោជន៍បន្ថែមលើសុខភាព** មានគុណប្រយោជន៍បន្ថែមយ៉ាងច្រើនទៅនឹងអនុសាសន៍របបអាហារខាងលើ។ ឧទាហរណ៍ ពួកវាអ្នកព្យាបាលជម្ងឺយ៉ាងល្អបំផុតចំពោះរោគទល់លាមក។

**រោគទល់លាមក** គឺជារបាំងដែលពិបាកនឹងឆ្លងកាត់។ ការញ៉ាំអាហារកំរិតខ្ពស់ដែលរួមមាន សណ្តែក សណ្តែកដី និង គ្រាប់ធញ្ញជាតិទាំងអស់ ផ្លែឈើស្រស់ និងបន្លែស្រស់។ ញ៉ាំយ៉ាងតិច ៨ មុខ កែវទឹកទំងន់៨ អោន (១អោន = ២៨.៣៥ ក្រាម) និងញ៉ាំទឹកផ្លែឈើក្នុង ១ថ្ងៃ។ ហាត់ប្រាណរៀងរាល់ពេល។ យកពេលណាមួយបន្ទាប់ពីញ៉ាំ អាហារពេលព្រឹក ឬ ពេលល្ងាចសំរាប់ទៅបង្គន់។ កុំបង្អាក់ដំណើរពោះវៀន។ យល់ថាទំលាប់ពោះវៀនតែងតែផ្លាស់ប្តូរជាធម្មតា។

## ➢ គន្លឹះទាំងប្រាំដើម្បីរបបអាហារប្រកបដោយសុខភាព

**១-អោយទារករបស់អ្នកបៅទឹកដោះម្តាយសម្រាប់៦ខែដំបូងនៃជីវិត**

-កើតមកភ្លាមរហូតដល់អាយុ ៦ខែ ទារកគួរទទួលការបៅដោះម្តាយ ទាំងថ្ងៃ ទាំងយប់។

-ការបំបៅដោយដោះម្តាយនៅពេលណាមួយទារករបស់អ្នកមានអារម្មណ៍ខឹង។

**២-ការញ៉ាំអាហារផ្សេងៗគ្នា**

-ការញ៉ាំលាយជាមួយអាហារខុសគ្នាៈ ម្ហូបអាហារសំខាន់ បន្លែអន្លក់ បន្លែ ផ្លែឈើ និងម្ហូបអាហារចេញពីសត្វ។

**៣-ការញ៉ាំបន្លែ និងផ្លែឈើដែលសំបូរដោយជីវជាតិ**

-បរិភោគបន្លែ និងផ្លែឈើដែលសំបូរជីវជាតិ

-ញ៉ាំបន្លែឆៅ និងផ្លែឈើដូចជាអាហារស្រស់ស្រួបដែលមានជាតិស្ករខ្ពស់ ឬ ខ្លាញ់

-នៅពេលចំអិនបន្លែ និងផ្លែឈើ ចៀសវាងចំអិនជ្រុលដែលអាចបាត់បង់ជាតិវីតាមីន។

**៤-ការញ៉ាំជាតិខ្លាញ់ និងប្រេងខ្លាញ់ចំនួនល្មម**

-ជ្រើសរើសសាច់ពណ៌ស (ឧទាហរណ៍ បសុបក្សី) និងត្រីដែលមានជាតិខ្លាញ់ទាបបន្ថែជាតិសាច់ពណ៌ក្រហម។

**៥-ការញ៉ាំអំបិល និងស្ករតិច**

-ចំអិន និងប្រៀបធៀបម្ហូបអាហារជាមួយជាតិអំបិលបន្តិចបន្តួចទើបប្រសើរ

-ចៀសវាងម្ហូបអាហារជាកំរិតអំបិលខ្ពស់

-ដាក់កំណត់ការហូរចូលនៃការផឹកទឹក និងទឹកផ្លែឈើដែលជាតិស្ករផ្អែម

## 38C. សកម្មភាពរាងកាយ ឬ សរីរាង្គ

សមតុល្យនៃអាហារដែលអ្នកញ៉ាំជាមួយសកម្មភាពនៃរាងកាយ។ ការហាត់ប្រាណគ្រប់គ្រាន់នឹងកាត់បន្ថយឱកាសនៃការឡើងសម្ពាធឈាម ជម្ងឺបេះដូង សរសៃឈាមក្នុងខួរក្បាល ដំបៅមហារីក និង ប្រភេទភាគច្រើននៃជម្ងឺទឹកនោមផ្អែម។

➢ **លក្ខណៈជីវិតអង្គុយច្រើន ( ការហាត់ប្រាណតិចតួច ) ( មើល** Section 41B)

ការហាត់ប្រាណជួយបេះដូងរបស់អ្នក និងរាងកាយឱ្យមាំមួន និងធ្វើការបានល្អ។ វាមានសម្ពាធឈាមទាបបង្កើនកម្រិតជាតិខ្លាញ់ កូឡេស្តេរ៉ូល និង អាចជួយដល់អ្នកក្នុងការសម្រេចទម្ងន់នោះជាបញ្ហាមួយ។ វាធ្វើឱ្យឆ្អឹងរបស់អ្នករឹងមាំ និង បង្កើនកម្រិតថាមពល និង ព្រលឹងវិញ្ញាណ ។

ឥឡូវមានការរីករាលដាលពាសពេញពិភពលោកនៃជម្ងឺធាត់ ដែលជាប់ទាក់ទងទៅនឹងគ្រប់វ័យទាំងអស់លើពិភពលោក។ សកម្មភាពនៃសរីរៈទាំងនេះគឺមានសារៈសំខាន់សម្រាប់បុរស ស្ត្រី និងកុមារ និងគ្រប់វ័យទាំងអស់។ WHO បញ្ជាក់ឱ្យដឹងអំពី

➢ **គន្លឹះទាំង៥នៃសកម្មភាពសរីរៈ**

១ -ប្រសិនបើអ្នកមិនបញ្ចេញសកម្មភាពសរីរៈណាមួយនោះទេ វាក៏មិនយឺតពេលដែរ ក្នុងការចាប់ផ្តើមសកម្មភាពសរីរៈជាទៀងទាត់ហើយបន្ថយការអង្គុយច្រើន។

២ -ធ្វើលំហាត់ប្រាណឬ សកម្មភាពសរីរៈជារៀងរាល់ថ្ងៃតាមមធ្យោបាយផ្សេងៗដែលអ្នកអាចធ្វើទៅបាន។

៣ -ធ្វើលំហាត់ប្រាណយ៉ាងហោចឱ្យបាន៣០នាទី នៃការកំដៅប្រាស្វា ឬ សាច់ដុំរបស់រាងកាយអាច ៥ ឬលើសពីនេះក្នុងមួយ សប្តាហ៍។

៤ -ប្រសិនបើធ្វើបាន នោះសកម្មភាពសរីរៈ នឹងមាំមួន លើសពីធម្មតា។

៥ -គួរលើកទឹកចិត្តសិស្សសាលាឱ្យធ្វើលំហាត់ប្រាណយ៉ាងហោច ៦០នាទី ដើម្បីពង្រឹងសកម្មភាពសរីរៈជារៀងរាល់ថ្ងៃ។

កំណត់សំគាល់នៅក្នុង Section 41 ជំងឺបេះដូង និង ជំងឺដាច់សរសៃឈាមក្នុងខួរក្បាលវាក៏ចូលក្នុងលក្ខខ័ណ្ឌជម្ងឺដុះក្បាលពោះ ជំងឺទឹកនោមផ្អែម និងជំងឺលើសឈាម ដែលសម្លាប់មនុស្សពេញវ័យរយៈពេលដ៏វែងឆ្ងាយជាងជម្ងឺដទៃទៀតនៅលើពិភពលោក។

មានកម្រិតនៃការប្រើប្រាស់ថ្នាំសម្រាប់លក្ខខ័ណ្ឌទាំងនេះ និង សូម្បីតែមួយចំនួនក៏មានសារៈសំខាន់ផងដែរ គ្រប់យ៉ាងផ្តល់ផលមិនល្អ។

របបអាហារ និង ការហាត់ប្រាណគឺជារឿងពីរសាមញ្ញបំផុត។ ដែលយើងធ្វើសម្រាប់ខ្លួនរបស់យើង និង គ្រួសាររបស់យើង អាចសង្រ្គោះជីវិតបានយ៉ាងច្រើន ហើយនឹង ការពារការឈឺចាប់បន្ថែមទៀតជាជាងប្រើឱសថ និង សិល្បសាស្ត្រ។

## 39.ជំងឺរលាកឆ្អឹង អូស្តេអូផូរ៉ូស៊ីស ឬ ជំងឺទឹកជ្រាបចូលក្នុងឆ្អឹង

សកម្មភាពសរីរៈនៃជីវិត នឹងជួយការពារជំងឺអូស្តេអូផូរ៉ូស៊ីស។ ជំងឺអូស្តេអូផូរ៉ូស៊ីស នឹងធ្វើឱ្យឆ្អឹងស្គម និង ការខូចឆ្អឹង ដែលបង្កឡើងដោយខ្វះសារធាតុកាល់ស្យូមមិនគ្រប់គ្រាន់។

កង្វះនៃកាល់ស្យូម និង វីតាមីនដេ បង្កឡើងរោគ Rickets នៅលើកុមារ។ វាបង្កឡើងផងដែរនូវការអន់ថយនៃការលូតលាស់របស់សារពាង្គកាយ និង ការលូតលាស់របស់ធ្មេញ។ ជំងឺអូស្តេអូផូរ៉ូស៊ីស គឺ កង្វះកាល់ស្យូមដែលជះឥទ្ធិពលដល់មនុស្សចាស់។ ជាពិសេសជះឥទ្ធិពលទៅលើស្ត្រី បន្ទាប់ពីអស់រដូវ និង លទ្ធផលក្នុងដំណើរបាក់ឆ្អឹងត្រគៀក ខ្នង និងតំបន់ផ្សេងដទៃទៀត។

➢ **ធ្វើតាមការបញ្ជាក់ WHO ដូចខាងក្រោមខណៈពេលដែលយើងជាកុមារអាចការពារ ជំងឺអូស្តេអូផូរ៉ូស៊ីសនៅពេលយើងក្លាយជាមនុស្សចាស់ :**

- ចៀសវាងការជក់បារី
- កុំក្រេបគ្រឿងស្រវឹង
- បំបៅទឹកដោះទៅទារក
- ការស្រូបចូលរបស់ជាតិកាល់ស្យូមយ៉ាងហោចណាស់៨០០ម.ក្រ ក្នុងមួយថ្ងៃសម្រាប់ក្មេងទៅ ១៥០០ ម.ក្រ សម្រាប់មនុស្ស ពេញវ័យក្នុងថ្ងៃ។ ទឹកដោះគោ (ជំនួយកម្លាំង ឬ ទឹកបរិសុទ្ធ, ឬ ភាពទៀតទាត់

ឬ ភាពមិនធាត់ ) គឺជាប្រភពល្អបំផុត នៃប្រភព កាល់ស្យូមសម្រាប់មនុស្សភាគច្រើន (៣៧៥មក្រ កាល់ស្យូមក្នុងមួយពែង )។ ញ៉ាំ៣ដង ក្នុង១ថ្ងៃ នឹងបង្កើតជាតិកាល់ស្យូម ដល់មនុស្សភាគច្រើន។ ប្រភពល្អបំផុតដទៃទៀតគឺទឹកដោះគោជូរ និងហ្វ្រូម៉ាស់ (ប៊ីរ)។ កាល់ស្យូមត្រូវបានគេរកឃើញក្នុងបន្លែពណ៌បៃតង ត្រីខកំប៉ុង និងត្រីសូម៉ង់។

➢ **ប្រភពល្អផងទៀតគឺតៅហ៊ូ ឬ សណ្តែក(Bean Curd)នៅពេលដែលវាបង្កើតអំបិលកាល់ស្យូម :**

- សកម្មភាពសិរីរៈ នៃជីវិតពេលខ្លះ (៥-១៥នាទីក្នុង១ថ្ងៃ) ចំណាយពេលនៅក្រៅផ្ទះ នឹងជួយការពារជំងឺអូស្តេអូផូរ៉ូស៊ីស។ ទោះបីជាយ៉ាងណាក៏ដោយ នេះគឺជាសារៈសំខាន់ដែលមិនទទួលបានច្រើនពីពន្លឺព្រះអាទិត្យ និង ការពារភ្នែករបស់អ្នក។ និង ជួយការពារមហារីកស្បែកអាយុមិនគ្រប់ខែ និងភ្នែកឡើងបាយ។ បើអាចជៀសបាន សូមកុំមើលពន្លឺព្រះអាទិត្យកណ្តាលថ្ងៃត្រង់។ ពាក់មួកការពារជម្ងឺភ្នែកឡើងបាយ និង ការបំផ្លាញដោយពន្លឺព្រះអាទិត្យផ្សេងៗដល់រាងកាយ និង អ្នកធ្វើការនៅខាងក្រៅផ្ទះ ឬ ក្រៅការិយាល័យ គួរតែពាក់មួកការពារ។

## 40. អាស៊ីតលំហូរ

សាមញ្ញបំផុតនោះបណ្តាលមកពីការចុកចាប់ពាក់កណ្តាលផ្នែកខាងលើពោះ ឬ ផ្នែកខាងក្រោមដើមទ្រូង គឺអាស៊ីតលំហូរបែបនេះ។ ហើយត្រូវបានគេហៅថា "ឆ្អល់ក្តៅដង្ហើម " ឬ "អាស៊ីតជំងឺចាក់ច្រាស " ឬ "អាស៊ីតអជីរណោ"។ វាមានឥទ្ធិពលលើសាច់ដុំជាប់នឹងបំពង់អាហារ(បំពង់ចិញ្ចឹម) ជាមួយក្រពះអាហារ។ រូបភាពបង្ហាញទីតាំងរវាងបំពង់អាហារ និងក្រពះ។

Reflux មានន័យថាការហូរត្រឡប់មកវិញ ឬ ហូរបកក្រោយ។ អាស៊ីតលំហូរកើតឡើងនៅពេល ស្តាញទ័រខ្សោយ ឬ សម្រាកមិនប្រក្រតីហើយធ្វើឱ្យបន្ទុកអាស៊ីតរបស់ក្រពះហូរឡើងទៅបំពង់អាហារ។

មាន**ច្រើនវិធីដែលអ្នកអាចការពារ និងព្យាបាលលក្ខខ័ណ្ឌជម្ងឺចុកចាប់ទាំងនេះ**

-កុំជក់បារីធ្វើឱ្យខ្សោយបំពង់អាហារស្តាញទ័រ និងបង្កើនការផលិតអាស៊ីត ដូច្នេះហើយអ្វីដែលសំខាន់បំផុតនោះគឺការ បញ្ឈប់ការជក់បារី។

-ចៀសវាងការញ៉ាំស្រាគឺមានមូលហេតុដូចគ្នាខាងលើ។

-អាហារផ្សេងៗអាចញ៉ាំឱ្យមានក៏រិតប្រសិនបើអាហារអាចបង្កឱ្យអ្នកឈឺ។ ទាំងនេះរួមទាំង ម្ទូបឆា និងអាហារ ខ្លាញ់ កាហ្វេ ភេសជ្ជៈកម្លោច និង អាហារក្តៅដូចជាម្រេច។

-ចៀសវាងញ៉ាំថ្នាំអាស្ពីរីន និងគ្មានជាតិថ្នាំ ស្តេរីយ៉ូដាល ដែលជាថ្នាំប្រឆាំងការរលាកសាច់ដុំដូចជា អ៊ីប៊ុយប្រូហ្វែន។

-ចៀសវាងចេកសំយ៉ុងក្បាលចុះរហូតដល់ ២ ទៅ ៣ ម៉ោងបន្ទាប់ពីការអាហាររួច។

-ធ្វើដំណើរទៅដើរកំសាន្តបន្ទាប់ពីញ៉ាំអាហាររួចរាល់ហើយ។

-ប្រសិនបើបញ្ហាខណៈកំពុងដេក ទំរេតមកខាងឆ្វេង (ដូចស្រ្តីកំពុងតែធ្វើ) និង/ឬ លើកក្បាលរបស់អ្នកកំពស់ ៤ ទៅ ៦អ៊ីងពីគ្រែ។

-សំរកទម្ងន់ប្រសិនបើលើសទម្ងន់។

-បន្ថយទំហំចន្លោះពេលវេលាញ៉ាំអាហារ (អ្នកអាចបង្កើនចំនួនបំបៅកូនប្រសិនបើអ្នកមិនលើសទម្ងន់)

-ទំពារស្ករកៅស៊ូ (គ្មានជាតិស្ករ) រយៈពេល ១ម៉ោង បន្ទាប់ពីញ៉ាំអាហារ។ ទាំងនេះនឹងបង្កើនទឹកមាត់ ប្រៃដែលអាច បន្សាបអាស៊ីតក្រពះ។

-អង់តាស៊ីត (ថ្នាំបន្សាបអាស៊ីត) អាចជួយកាត់បន្ថយជម្ងឺ។ កាល់ស្យូមអង់តាស៊ីត គឺចាំបាច់ត្រូវតែមាន ពីព្រោះវាអាចជួយការពារបញ្ហាធម្មតា៧ដទៃទៀត អូស្តេអូផូរ៉ូស៊ីស (ជម្ងឺស្ពមឆ្អឹង) មើល section 39. ទោះបីជាយ៉ាងណាក៏ ដោយ ពេលខ្លះកាល់ស្យូមអង់តាស៊ីតបង្កមកពី "ការកកើតឡើងវិញដោយសម្ងាត់របស់អាស៊ីត" ដូចនេះកុំប្រើពួកវា ប្រសិនបើពួកវាធ្វើអោយជម្ងឺរបស់អ្នកធ្ងន់ធ្ងរឡើងៗ។

## 41A. ជម្ងឺបេះដូង និងសរសៃឈាមខួរក្បាល

មានរោគឆ្លងរាលដាលដែលបណ្តាលឱ្យស្លាប់ព្រោះតែជម្ងឺបេះដូងនៅលើប្រទេសកំពុងអភិវឌ្ឍន៍។ ទាំងនេះអាចជាកិច្ចការពារដូចជាមូលហេតុដែលស្ថិតក្រោមការគ្រប់គ្រងរបស់អ្នក។

ជម្ងឺសរសៃឈាមខួរក្បាល និងជម្ងឺបេះដូងអាចជាឥទ្ធិពលប្រថុយប្រថានដែលអ្នកអាចគ្រប់គ្រងរួមមាន : **ការជក់បារី លើសទំងន់ សម្ពាធឈាមខ្ពស់ ខ្លាញ់ក្នុងឈាមខ្ពស់ ដំណើរជីវិតអង្គុយច្រើន(ហាត់ប្រាណតិចតួច) រោគទឹកនោមផ្អែម ក៏រិតសម្ពាធខ្ពស់ និងស្រ្តេស។**

### ➢ ការជក់បារី :

យើងបានពិភាក្សារួចរាល់ហើយនូវឥទ្ធិពលគ្រោះថ្នាក់នៃការជក់បារីដូចជាតំរងជ័រ និងជម្ងឺធ្មេញ បញ្ហា ក្រពះ និងមានបន្តទៀត។ បារីមានទំនាក់ទំនងជាមួយជម្ងឺដែលការនាំឱ្យមនុស្សស្លាប់។

**នីកូទីន** (សារធាតុផ្សំសំខាន់នៅក្នុងបារី) គឺជាការបន្ថែមជាតិញៀនក៏រិតខ្ពស់ នៅពេលចាប់ផ្តើមជក់បារីដែលវា

ពិបាកដើម្បីបញ្ឈប់វា។

ការជក់បារីបង្កឱ្យមានជម្ងឺបេះដូង ដាច់សរសៃឈាមរបស់ខួរក្បាល ជម្ងឺសរសៃឈាមដែលនាំមកនូវការកាត់អវៈយវៈណាមួយ រោគរលាកទងសួត គ្រប់យ៉ាងនៃជម្ងឺទាំងនេះដូចបានបង្ហាញទីនេះស្រាប់។ វាក៏បង្កផងដែរនូវរោគមហារីកសួត អ៊ឹមភីសេម៉ា រោគរលាកទងសួត និងជម្ងឺផ្សេងពីនេះច្រើនទៀត។

**ការបញ្ឈប់ការជក់បារីគឺជារឿងសំខាន់ដែលអាចជួយការពារជម្ងឺទាំងនេះ និងជាឥទ្ធិពលប្រសើរជាងប្រើប្រាស់ថ្នាំ**

ប្រសិនបើការជក់បារីនៅផ្ទះរបស់អ្នក ការស្រូបខ្យល់បារី គឺបង្កជម្ងឺដូចជាអាស្មា (រោគហឺត) មហារីក និងសម្លាប់ ទារកដែលជាទីស្រឡាញ់តែមួយគត់ភ្លាម។ផងដែរ។ ភស្តុតាងវិទ្យាសាស្ត្រ គឺលើសលុបបំផុតដែលគ្មានអត់ទោសសម្រាប់នរណាម្នាក់ឡើយ កន្លែងណាមួយ ដែលជក់បារីគ្រប់ពេលនោះ។

## 41B. ជម្ងឺបេះដូង និងជម្ងឺសរសៃឈាមខួរក្បាល

ជម្ងឺបេះដូង និងជម្ងឺសរសៃឈាមខួរក្បាលផ្សេងទៀត គឺជាភាគរយប្រថុយប្រថានដែលអ្នកអាចគ្រប់គ្រងបានរួមមាន:

- **លើសទំងន់ :**

(មើល section 38. NUTRITION & PHYSCIAL ACTIVITY)

ការលើសទំងន់ខ្លាំងអាចបង្កើនភយន្តរាយសម្រាប់ការវិវឌ្ឍន៍បញ្ហាសុខភាពរួមមាន ជម្ងឺបេះដូង សរសៃឈាមខួរក្បាល វាយ ២ (ផ្តែកផ្តើមពីយុវជន) រោគទឹកនោមផ្អែម រោគមហារីក និងជម្ងឺធ្ងន់ធ្ងរដទៃទៀត។ អ្នកអាចមានគ្រោះថ្នាក់ខាងសុខភាពក៏រិតទាបដោយការបាត់បង់ទម្ងន់បន្តិចបន្តួចចាប់ពី ១០ទៅ ២០ ផោន។ កំណត់ចំនួនការញុាំ និងហាត់ប្រាណកន្លះម៉ោងជារៀងរាល់ថ្ងៃ។

- **កំរិតឈាមខ្លាញ់ក្នុងប្រម៉ាត់ :**

(មើល SECTION 38. NUTRITION & PHYSCIAL ACTIVITY)

ទាំងនេះអាចត្រូវបានគេគ្រប់គ្រងដោយកាត់បន្ថយចំនួនខ្លាញ់សត្វសម្រាប់របបអាហាររបស់អ្នក។ មានទាំងថ្នាំដែលអាចជួយ។ កំរិតខ្លាញ់ក្នុងប្រម៉ាត់អាចធ្វើឱ្យប្រសើរឡើងដោយការហាត់ប្រាណ។

- **ដំណើរជីវិតអង្គុយច្រើន ( ការហាត់ប្រាណតិចតួច) :**

(មើល SECTION 38C PHYSCIAL ACTIVITY)

ការហាត់ប្រាណជួយឱ្យបេះដូងរបស់អ្នក និងរាងកាយរបស់អ្នកខ្លាំង និងធ្វើការងារល្អ។ វាមានសម្ពាធឈាមតិចតួច។ វាក៏ធ្វើឱ្យប្រសើរឡើងកំរិតជាតិខ្លាញ់ និងអាចជួយឱ្យអ្នកស្រកទំងន់ប្រសិនបើជាបញ្ហា។ វាក៏ធ្វើឱ្យប្រសើរឡើងផងដែរ កំរិតថាមពល(កម្លាំង) និងធ្វើឱ្យឆ្អឹងរឹងល្អ។

## ➢ រោគទឹកនោមផ្អែម( ប្រភេទ ២ ឬផ្អែកធ្ងើមរបស់យុវជន) :

( មើល SECTION 38. NUTRITION & PHYSCIAL ACTIVITY )

បានគ្រប់គ្រងរោគទឹកនោមផ្អែមយ៉ាងខ្សោយបំផុត ហើយធ្វើឱ្យអ្នកបង្កើតគ្រោះថ្នាក់ នៃរោគបេះដូង និងសរសៃឈាមខួរក្បាលដូចគ្នានឹងជម្ងឺខ្វាក់មាន់ និងជម្ងឺស្ពឹកដៃជើង។ ទោះបីជាយ៉ាងណាក៏ដោយ ការដាក់ថ្នាំគឺតែងតែមានភាពចាំបាច់ ការតមអាហារ ការបន្ថយទំងន់ និងការហាត់ប្រាណដូចដែលបានបង្ហាញដែលជា ប្រសិទ្ធិភាពបន្ថែមច្រើនជាងការប្រើប្រាស់ថ្នាំនៅក្នុងកិច្ចការពារនិងគ្រប់គ្រងលើរោគទឹកនោមផ្អែមរបស់មនុស្សជំទង់។

វាជាសារវន្តដែលអ្នកមិនដែលជក់បារី (រមែងជាលទ្ធផលលើ ជម្ងឺស្ពឹកដៃជើង)។ អាល់កុល (សុរា) គឺជាសារធាតុពុល តុស៊ីកទៅលើអ្នកជម្ងឺទឹកនោមផ្អែម និងអាចមានរោគទឹកនោមផ្អែមធ្ងន់ធ្ងរឡើងដែលមិនអាចបំផ្លាញកាត់បន្ថយ និង សំពាធឈាមឡើងខ្ពស់។

ដើម្បីជួយរក្សាឈាមដែលមានជាតិស្ករចំពោះកំរិតសុខភាពអ្នកគួរ :

១-ញ៉ាំចំនួនអាហារដូចគ្នាមួយថ្ងៃៗ

២-ញ៉ាំពេលដូចគ្នារៀងរាល់ថ្ងៃ

៣-ញ៉ាំថ្នាំពេលដូចគ្នាជារៀងរាល់ថ្ងៃ

៤-ហាត់ប្រាណពេលដូចគ្នាជារៀងរាល់ថ្ងៃ

ញ៉ាំផ្លែឈើ បន្លែ ផលិតផលមានជាតិខ្លាញ់កំរិតទាបខុសៗគ្នា និងញ៉ាំម្ហូបអាហារធុញ្ញជាតិជារៀងរាល់ថ្ងៃ។ ទាំងនេះជាអាហារដែលអ្នកគួរបរិភោគជាដំបូង។ ពួកវាផ្តល់វីតាមីនជាច្រើន អំបិលខនិជ និងសរសៃសាច់ដុំជាស្រេចដែលពួកគេផ្តល់ជាតិកាឡូរីបន្តិចបន្តួច ដូច្នេះអាចជួយអ្នកគ្រប់គ្រងជាតិស្កក្នុងឈាម ដូចជាការសម្រកទំងន់។ បន្លែភាគច្រើន គឺមានទំនាក់ទំនងទាបនៅក្នុងកាបូអ៊ីត្រាត ដូចនេះជាការជ្រើសរើសពិសេសល្អបំផុត។

## ➢ សំពាធឈាមខ្ពស់ :

( មើល SECTION 38. NUTRITION & PHYSCIAL ACTIVITY )

មនុស្សភាគច្រើន ជាមួយសំពាធឈាមខ្ពស់គ្មានអារម្មណ៍ឈឺទេ។ នេះគឺជាកំរិតសម្ពាធឈាមខ្ពស់ដែលបានគេហៅថា “Silent Killer” អ្នកសម្លាប់ស្ងាត់ស្ងៀម។ មូលហេតុនេះគឺសំខាន់ណាស ដើម្បីព្យាបាលសំពាធឈាមខ្ពស់

គឺមូលហេតុមកពីវាបង្កឱ្យមាន ការវាយប្រហារដោយជម្ងឺបេះដូង និងរោគដាច់សរសៃឈាមខួរក្បាល។ ជាសំណាងល្អ មានមធ្យោបាយជាច្រើនដើម្បី កាត់បន្ថយសំពាធឈាមខ្ពស់។

ការតមអាហារបានផ្លាស់ប្តូរប្រសិទ្ធិភាពការព្យាបាលភាគច្រើនរួមមាន :

- កាត់បន្ថយអំបិលនៅក្នុងការតម
- បង្កើនប៉ូតាស្យូម (ចេក និងផ្លែឈើស្រស់ៗ និងបន្លែស្រស់ៗ)
- ការកំណត់ផ្សេងទៀតដូចជាការពណ៌នានៅក្នុង Section 38.

សំពាធឈាមត្រូវការពិនិត្យយ៉ាងយកចិត្តទុកដាក់ពីក្រុមគ្រូពេទ្យ។ ប្រសិនបើក្រុមគ្រូពេទ្យដាក់ថ្នាំឱ្យអ្នកនៅសំពាធឈាមខ្ពស់គឺវាមានសារៈសំខាន់ថាអ្នកលេបថ្នាំបន្តជារៀងរាល់ថ្ងៃ សូម្បីតែអ្នកមិនមានថាឈឺក៏ដោយ។ តែងតែមើលអ្នកមុននឹងឈប់លេបថ្នាំសំពាធឈាមខ្ពស់ (សូម្បីតែមុននឹងផ្អាកការឱ្យថ្នាំម្តង)។ ការបញ្ឈប់លេបភ្លាមៗអាចបង្កឱ្យសំពាធឈាមងើបឡើងវិញដែលមានកំរិតខ្ពស់ និងគ្រោះថ្នាក់ និងអាចបង្កឱ្យការវាយប្រហារបេះដូង និងសរសៃឈាមខួរក្បាល។ ដូចនេះវាមានសារៈសំខាន់ណាស់ដែលអ្នកគួរបន្តលេបថ្នាំជាទៀតទាត់ដោយស្តាប់តាមបញ្ជាក្រុមគ្រូពេទ្យ ដូចនេះគាត់អាចតាមដានសំពាធឈាមរបស់អ្នក និងកែសម្រួលថ្នាំរបស់អ្នក។

ស្ត្រេស : ស្ត្រេសអាចនាំមុខនៃការវាយប្រហារដោយជម្ងឺបេះដូង និងជម្ងឺសរសៃឈាមខួរក្បាល និងផ្សេងទៀតមកពីបញ្ហាសុខភាព។ មនុស្សមួយចំនួនទទួលខុសត្រូវចំពោះស្ត្រេសដោយការញ៉ាំលើស។ ការសិក្សាបានបង្ហាញថាអ្នកជម្ងឺដែលបន់ស្រន់ និងមានអារម្មណ៍ខាងផ្លូវចិត្តសង្កត់ធ្ងន់លើសេចក្តីស្រឡាញ់ និងការអត់ឱនទំនងជាគ្រប់គ្រងស្ត្រេសបានល្អជាង និងទទួលខុសត្រូវល្អបំផុតដើម្បីព្យាបាល។ ការតមអហារ ការហាត់ប្រាណទៀងទាត់ពេលវេលា និងចៀសវាងផលិតផលបារីដែលជារឿងសាមញ្ញចំនួន៣ និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នក និងការគ្រប់គ្រងតែមួយគត់។

## 42A.វិធីព្យាបាលការឈឺចាប់ខ្នង

**ដំណើរបន្តបន្ទាប់នៃការឈឺឆ្អឹងខ្នងស្រួច** អាចព្យាបាលជាមួយទឹកកកទៅលើតំបន់នោះ ក្នុងរយៈពេល៦ម៉ោងដំបូងបន្ទាប់ពីរបួស។ ទាំងនេះអាចបន្តក្នុងរយៈពេល២ថ្ងៃដំបូងដើម្បីបន្ថយការហើម។ បន្ទាប់ពីកំដៅ៣ថ្ងៃហើយនោះអាចជួយឱ្យសះមុខរបួសបាន។

- ថ្នាំបំបាត់ការចុកចាប់ដូចជា ប៉ារ៉ាសេតាម៉ុល
- សកម្មភាពដែលដាក់កម្រិតក្នុងរយៈពេល២ថ្ងៃដំបូង និង បន្ទាប់មកបង្កើនកំរិត ចាប់ផ្តើមសណ្តូក និងធ្វើលំហាត់ប្រាណធម្មតា ដូចជា ដើរជាដើម។ អ្នកដែលមានជំងឺឈឺខ្នងស្រួច គួរតែធ្វើចលនា និងបន្តធ្វើចលនារៀងរាល់ថ្ងៃឱ្យបានច្រើនដងដែលអាចធ្វើទៅបាន។ ពួកគេគួរតែចៀសវាងអង្គុយយូរ

ឧស្សាហ៍ងើបចុះងើបឡើង ឬ ពត់ខ្នងចុះឡើងៗឆ្វេងស្តាំ និង យកចិត្តទុកដាក់ ជាពិសេសលើការកែតំរូវនូវឥរិយាបថការធ្វើចលនាជារាល់ថ្ងៃរបស់លោកអ្នក។

- ចំណាំថា ពូក និង ខ្នើយ ដែលរឹងដាក់នៅចន្លោះជើងទាំងពីរអាចជួយការពារជម្ងឺឈឺខ្នង។ កត់សំគាល់ផងដែរ ប្រដាប់ទល់ជើង របស់មនុស្សប្រុសគឺដាក់នៅលើប្រអប់មួយ។ ទាំងនេះនឹងជួយដល់ការឈឺចាប់ខ្នង ប្រសិនបើអ្នកមានការងារដែលតំរូវឱ្យអង្គុយយូរនោះ។
- ប្រសិនបើហេតុការណ៍ឈឺចាប់កន្លងហើយក្នុងរយៈពេល៦សប្តាហ៍ ឬ ក៏មានអាការៈដទៃទៀតដូចជាគ្រុន ឬ ស្រកទម្ងន់ ឬ ការទប់ទឹកនោម អ្នកគួរតែទៅមណ្ឌលសុខភាព ដើម្បីពិនិត្យសម្រាប់ការយល់ដឹងបន្ថែមដែលអាចធ្វើទៅបាន។
- បន្ទាប់ពីការឈឺចាប់ឆ្អឹងស្រួចបានអន់ ធ្វើចលនាសណ្តូកដែលអាចជួយឱ្យជាសះស្បើយនូវឆ្អឹងខ្នង និង ជួយការពារអេពីសូដ (episode) បន្ថែម។

ទាំងនេះគួរតែធ្វើជារៀងរាល់ថ្ងៃ និង ជាការធ្វើដ៏ល្អបំផុតនោះ បន្ទាប់ពីអ្នកបានធ្វើចលនាកំដៅសាច់ដុំ។ ការធ្វើចលនាគួរតែធ្វើមួយៗ និង មិនកន្ត្រាក់យ៉ាងហោចណាស់ក៏ក្នុងរយៈពេល ៣០វិនាទី។ មុខងារមួយចំនួនអាចធ្វើក្នុងរយៈពេល ១០ ទៅ ១៥នាទី ប្រសិនបើមានអារម្មណ៍សុះសាយក្នុងចិត្ត និងធូរស្បើយច្រើន។

**ឧទាហរណ៍ ការធ្វើចលនាសណ្តូក រួមមាន :**

- ដេកសណ្តូកលើការ៉ូ : នេះគឺជាប្រយោជន៍សម្រាប់ព្យាបាលរបួសថ្មីៗ។ លើកជើងដាក់នៅលើ footrest (ប្រដាប់គងជើង) ឬ កៅអីពូក ដែលទាំងនេះអាចសម្រួលសាច់ដុំ ដូចនេះអ្នកជម្ងឺ គួរតែធ្វើឱ្យបានយ៉ាងតិចក៏ ១៥នាទី ឬ ច្រើនជាងនេះ។
- ការអង្គុយ : ការបង្អែកលើកៅអី និងងោកក្បាលចុះទៅលើក្បាលជង្គង់យ៉ាងហោចណាស់ធ្វើអោយបាន ៣០វិនាទី ឬ ធ្វើច្រើន ជាងនេះប្រសិនបើមានអារម្មណ៍ថាស្រួលខ្លួន។
- ការឈរ : យកដៃទាំងពីរលើកឡើងលើបោះទៅក្រោយក្នុងរយៈពេល ៣០វិនាទី ឬ លើសពីនេះប្រសិនបើមានអារម្មណ៍ថាស្រួល ខ្លួន។

## 42B.ការព្យាបាលជម្ងឺឈឺឆ្អឹងខ្នង (ធ្វើបន្ត)

ការហាត់ប្រាណគឺជួយពង្រឹងសាច់ដុំខ្នង។ បន្ទាប់ពីមានជម្ងឺឈឺឆ្អឹងស្រួចបានអន់គ្រឡប់ទៅហាត់ប្រាណជារៀងរាល់ថ្ងៃ។ នេះគឺជាជំរើសដ៏ល្អបំផុតសម្រាប់ការកំដៅសាច់ដុំ ដោយការដើរ និង សណ្តូក មុននឹងធ្វើលំហាត់ប្រាណ។ កុំហាត់ប្រាណនៅពេលមានការ ឈឺឆ្អឹងឆ្អែង។

➢ **ខាងក្រោមនេះគឺជា ឧទាហរណ៍នៃការធ្វើលំហាត់ប្រាណ ដែលត្រូវសណ្តូកសាច់ដុំឆ្អឹងខ្នង :**

- ផ្សៀងត្រគៀក : នេះគឺលំហាត់ប្រាណដ៏ល្អដែលនឹងត្រូវធ្វើ ជាពិសេសចំពោះអ្នកដែលមានរបួសឆ្អឹងខ្នងថ្មីៗ។ ដេកសណ្តូកខ្នង ដើម្បីរលាស់ជើងទាំងពីរត្រង់ក្បាលជង្គង់ចុះឡើងៗ។ ផ្សៀងត្រគៀករបស់អ្នកឱ្យទៅដល់ខាងក្រោមឆ្អឹងខ្នងឱ្យជាប់ទៅនឹងកម្រាលឥដ្ឋ ដោយបង្រួមសាច់ដុំពោះ និង កំប៉េះគូថ។ ធ្វើរយៈពេល ៥ ទៅ ១០ វិនាទី រួចសម្រាក។ ធ្វើ ១០ ទៅ ១២ ដង សារ ចុះសារឡើង។ ធ្វើបីដង។ (ការហាត់ប្រាណគឺងាយក្នុងការធ្វើ ប្រសិនបើធ្វើចលនាបោះដៃទាំងពីរជុំវិញរាងកាយរបស់អ្នកប្រសើរជាងការធ្វើលំហាត់ប្រាណងើយក្បាលទៅក្រោយ ដូចបង្ហាញនៅក្នុងរូបភាព)
- **កង់ :** យកខ្នងរបស់អ្នកមកដេកសណ្តូកកន្លែងរាបស្មើ រលាស់ជើងទាំងពីរត្រង់ក្បាលជង្គង់ និង ពត់ត្រគៀកចុះឡើងៗ។ បត់ និង ពន្យឹតឆ្លាស់គ្នានៅចលនាធាក់កង់។ ធ្វើបីដង ឬ ច្រើនជាងនេះ ប្រសិនបើមានអារម្មណ៍ថាស្រួល។ កុំដកដង្ហើម ឬ ប្រើចលនាកន្ត្រាក់។ (ប្រសិនបើអ្នកមានរបួសឆ្អឹងខ្នងវាអាចធូរស្បើយ ដោយយកដៃទាំងពីរបង្វិលព័ទ្ធជុំវិញរាងកាយប្រសើរជាងងើយក្បាលទៅក្រោយ ដូចបង្ហាញនៅលើរូប)
- **អង្គុយកាន់ជើងម្ខាងងើប ឬ ពួស្ទូរត្រីបៗ** ជាការបញ្ជាក់បង្ហាញ។ ចាប់ផ្តើមយកខ្នងរបស់អ្នកដេកលើកន្លែងស្មើជាមួយជើងទាំង ពីររលាស់ត្រង់ត្រគៀក។ យកដៃទាំងពីររបស់អ្នកដាក់ខ្វែងគ្នាកាត់ដើមទ្រូង។ អ្នកអាចយកជើងម្ខាងយកទៅដាក់លើជ្រុងគ្រែ ឬ បំណែករឹងរបស់សង្ហារឹម។ ងើបក្បាល និង ស្មារចុះឃើតៗទៅនឹងកម្រាលឥដ្ឋ។ ធ្វើឱ្យបានបីដង ឬ ច្រើនជាងនេះ។ ធ្វើសារជា ថ្មីពី ៥ ទៅ ១០នាទី ឬ ធ្វើលំហាត់ប្រាណផ្សេងដទៃទៀត។ កុំអត់ដង្ហើម ប្រើចលនាកន្ត្រាក់ ឬក៏ធ្វើលំងាកករបស់អ្នក។

## 43.របៀបការពារជម្ងឺឈឺឆ្អឹងខ្នង

**មានច្រើនរបៀបដែលអ្នកអាចការពារភាពចុកចាប់ និងជូនកាលមានលក្ខខ័ណ្ឌមិនគ្រប់គ្រាន់។**

**ជារៀងរាល់ថ្ងៃការដេកសណ្តូក និងលំហាត់ប្រាណឆ្អឹងខ្នង** (ដូចដែលបានពណ៌នានៅ Section 42A និង 42B) សម្រាប់ការព្យាបាលគឺស័ក្តិសិទ្ធិបំផុតនៅក្នុងការការពារ និង ថែរក្សាការឈឺចាប់ឆ្អឹងខ្នង។ ខាងក្រោមនេះក៏សំខាន់ផងដែរ :

- កុំជក់បារី
- សម្រកទម្ងន់ នឹងជួយដល់អ្នក នៅពេលដែលអ្នកឡើងទម្ងន់ ឬ ឡើងគីឡូ

- ងើបចុះងើបឡើងជាញឹកញ៉ាប់ ។ ឱនអោយហួសនៅពេលដែលអ្នកងើប ។ ជានិច្ចកាលធ្វើយ៉ាងណាឱ្យឆ្អឹងខ្នងត្រង់ និង បត់ក្បាលជង្គង់របស់អ្នក ។ ទាំងនេះនឹងអនុញ្ញាតិឱ្យអ្នកលើកជើងទាំងពីរជំនួសឱ្យឆ្អឹងខ្នង ។ កុំបែរ ឬ បត់បែនដើម្បីឈោងយកអ្វីមួយ សូម្បីតែនៅពេលភ្លឹក៏ដោយ ។ ទុករបស់នៅក្បែរខ្លួនដែលអាចធ្វើទៅបាន ។
- ប្រើឥរិយាបថល្អៗខណៈពេលអង្គុយ និង ឈរ ។ ប្រសិនបើការងាររបស់អ្នកតំរូវឱ្យឈរយូរ ឧស្សាហ៏លើកជើងដាក់លើជើងម៉ា ដើម្បីជួយរក្សាខ្នងឱ្យត្រង់ ( មើល SECTION 42A ) ។
- ប្រើបង្អែកពូករឹងខណៈពេលកំពុងអង្គុយ ឬ ឈរ ឬដូរបង្អែកពូកដាក់លើក្តារ ឬ កម្រាលឥដ្ឋ ។ យកខ្នើយដាក់ពីក្រោមជើងទាំងពីរប្រសិនបើអ្នកដេក ។ ដូរខ្នើយចន្លោះជើងទាំងពីរ ប្រសិនបើអ្នកដេកចំហៀង ( មើល SECTION 42A ) ។ កុំដេកផ្កាប់មកនាំឱ្យកល់ពោះ ។

## 44. ការបង្ការគ្រោះថ្នាក់សម្រាប់ទារក និងក្មេងអាយុពី ២ ទៅ ៣ឆ្នាំ

### ➢ សហនិមិត្តហេតុនៃការស្លាប់របស់ទារកភ្លាមៗ :

ជួនកាលទារកស្លាប់ដោយមិនទឹកស្ទានដល់ខណៈទារកទាំងនោះកំពុងតែដេក ។ នេះគឺតែងតែចូលរួមជាមួយនឹងជម្ងឺក្អក និងថ្នាំត្រជាក់ខ្លួន ឪពុកម្តាយជក់បារី និងដាក់ទារកដើម្បីដេកផ្កាប់មុខជាដើម ។ កុំប្រើភួយ ឬ យករបស់ទន់ៗដាក់លើគ្រែរបស់ទារក ។ ជាទូទៅដាក់ទារកឱ្យដេកនៅលើខ្នងរបស់ទារក ហាមជក់បារី ។

### ➢ ជាតិពុល :

នេះគឺជាមូលហេតុពិសេសសាមញ្ញមួយនៃមរណៈលើកុមារដែលមានអាយុតិចជាង ៣ ឆ្នាំ ។ ក្មេងៗអាចដាក់វត្ថុអ្វីមួយនៅក្នុងមាត់របស់ពួកវា ។ ថ្នាំសាមញ្ញជាច្រើន និងផលិតផលគ្រឿងទេសគឺជាជាតិពុល និងបណ្តាលឱ្យមានមរណៈកុមារ ។

### ➢ វិធីដែលអ្នកអាចបង្ការមរណៈភាពពីជាតិពុល :

- រក្សាគ្រប់ឱសថទាំងឡាយដោយចាក់សោរ និងមិនឱ្យឃើញពីភ្នែក ។
- រក្សាគ្រប់ជាតិគីមី និងគ្រឿងផ្សំដោយចាក់សោរ និងមិនឱ្យឃើញពីភ្នែក ។
- បង្រៀនក្មេងៗកុំឱ្យផឹក ឬ ញ៉ាំវត្ថុអ្វីមួយលុះត្រាតែមនុស្សធំឱ្យ ។
- ព្យាយាមកុំយកឱសថឱ្យក្មេងឃើញ ។ ក្មេងៗយកចិត្តទុកដាក់ចម្លងសកម្មភាពរបស់មនុស្សធំ ។

**ការឈ្លក់** គឺជាមូលហេតុសាមញ្ញខ្លាំងបំផុតនៃការស្លាប់របស់កុមារអាយុក្រោម ៥ ឆ្នាំ ។

➢ **វិធីដែលអ្នកអាចការពារការស្លាប់ពីការឆ្លាក់ :**

-កុំឱ្យគ្រាប់ផ្លែឈើរឹង ពោតលីង សណ្ដែកគ្រាប់រឹង សាច់ក្រក ឬ ចំណីអាហារផ្សេងៗ ដែលមានទំហំស្រដៀងគ្នាទាំងនេះដល់ កុមារ ។

-តែងតែកាត់ជាដុំៗនូវអាហារក្មេង (ជាពិសេសអាហារដូចជា សាច់ចំណិតធំៗ) ទៅជាបំណែកតូចៗ ។ ចំមនុស្សវ័យចំណាស់ដែលមិនមានធ្មេញគួរតែធ្វើយ៉ាងដូចនេះដែរ ។

-កុំឱ្យក្មេងៗលេងជាមួយប៉េងប៉ោង កូនឃ្លី ឬរបស់ក្មេងលេងជាមួយផ្នែកតូចៗដែលពួកវាអាចឆ្លាក់បាន ។

-ប្រសិនបើកូនរបស់អ្នកតិចជាង ៥ ឆ្នាំ និងគប្បីយកថ្នាំគ្រាប់ ឬ វីតាមីន "chewable" កិនឱ្យហ្មត់ជាម្សៅឱ្យបាន២ ស្លាបព្រា ។ បន្ទាប់មកទៀតអ្នកអាចលាយម្សៅថ្នាំទាំងនោះជាមួយទឹក ឬអាហារ ។

## 45. ការលង់ទឹក / ជួល / ការគ្រោះថ្នាក់ចរាចរណ៍

គ្រោះថ្នាក់គឺសំខាន់បំផុត ដែលនឹងបណ្ដាលឱ្យបាតបង់ជីវិតដល់ក្មេងៗដែលមានអាយុនឹងទៅសាលារៀន ។ ក្មេងៗដែលមានអាយុបែបនេះ គឺធ្វើទៅតាមតែចិត្តរបស់ពួកគេ ។ ពួកគេមិនចង់ធំធាត់ឡើងនៅក្រោមច្បាប់ស្ដាប់បង្គាប់ទេ ។

-កូនរបស់អ្នកគឺមិនមានសុវត្ថិភាពល្អ នៅក្នុងទឹកតែម្នាក់ឯងទេ សូម្បីបើសិនជាគាត់ ឬ នាងដឹងបីរបៀបហែលទឹកក៏ដោយ ។ ចូរកុំឱ្យកូនៗរបស់អ្នកទៅលេងទឹកដែលគ្មានមនុស្សពេញវ័យមើលថែរក្សាឱ្យសោះ ។ មិនត្រូវឱ្យកូនរបស់អ្នកហែលទឹកនៅតាមព្រែក ឬ ទឹកហូរលឿននោះទេ ។

-ចូរបង្រៀនកូនរបស់អ្នកលេងទឹក ដោយយកជើងទៅមុនសិន (ការជ្រមុជទឹកយកក្បាលទៅមុន អាចនឹងបណ្ដាលឱ្យបែកក្បាល បាក់ក ខ្វិនដៃជើងរហូត) ។

-បង្រៀនកូនពៅរបស់អ្នកដែលមិនធ្លាប់ឆ្លងកាត់ផ្លូវដោយមានអ្នកនាំផ្លូវ ។ ចូរបង្រៀនដល់កូនច្បងរបស់អ្នកឱ្យចេះឈប់នៅចិញ្ចើមថ្នល់ បន្ទាប់មកឱ្យក្រឡេកមើលឆ្វេង ស្ដាំ និងងាកបែរទៅឆ្វេងវិញម្ដងទៀតមុនពេលដែលដើរឆ្លងកាត់ ។

-ចូរប្រើប្រាស់ខ្សែក្រវ៉ាត់ជានិច្ចនៅពេលនៅក្នុងរថយន្ត ឬ រថយន្តធំៗ បើសិនជាបួកគេមានវា ។

## 46. រោគឆ្កួត / ការដក់ចារីក្នុងបន្ទប់

➢ **រោគឆ្កួត :**

ឆ្កែខាំ ឆ្មាខាំ ប្រជៀវខាំ សំពោចខាំ ឬ សត្វដទៃទៀតអាចបង្កឱ្យមានរោគឆ្កួត ។ រោគឆ្កួតគឺជាជម្ងឺដែលតែងតែ

ចៀសមិនរួចម្តង១ដែលជម្ងឺកើតឡើង។ ទោះបីជាយ៉ាងណាក៏ដោយ ឥទ្ធិពលព្យាបាលគឺ អាចទៅរួចប្រសិនបើវាត្រូវបានគេប្រើមុននឹងជម្ងឺកើតឡើង។ ដូច្នេះវាគឺមានសារៈសំខាន់បំផុតដើម្បីស្វែងរកការការពារជាប្រញាប់ដែលអាចធ្វើទៅបានបន្ទាប់ខាំរួចភ្លាម។

➢ **ការបង្ការពីឆ្កែខាំ :**

មេរៀនសំខាន់បំផុតសម្រាប់កុមារ១ដើម្បីរៀននោះគឺកុំអោយលលេងជាមួយឆ្កែ និងចៀសឱ្យឆ្ងាយពីឆ្កែដែលក្មេង១មិនដែលស្គាល់។ កុំរំខានឆ្កែខណៈពេលដែលវាដេក ស៊ីអាហារ ប្រឡែងជាមួយរបស់ក្មេងលេង ឬ កំពុងពាំកូនរបស់វា។

➢ **ប្រៀនប្រដៅកូនរបស់អ្នកប្រតិបត្តិតាមដូចជា :**

ឈរស្ងៀមប្រសិនបើអ្នកចូលទៅជិត ឬ ដេញដោយឆ្កែចម្លែក។ កុំរត់ ជិះកង់ ទាត់ ឬ ធ្វើកាយវិការបន្លាច។ ក្រោកឈរឱ្យត្រង់ និងនៅស្ងៀមដាក់ដៃទៅផ្នែកម្ខាង និងចៀសវាងប្រើភ្នែកសម្លឹងមើលឆ្កែ។ មិនត្រឡប់ខ្នងរបស់អ្នកទៅរកឆ្កែ។ គ្រាមួយនោះហើយដែលឆ្កែបាត់បង់ការចាប់អារម្មណ៏លើអ្នក ត្រឡប់ក្រោយយឺត១រហូតដល់វាមើលមិនឃើញ។ ប្រសិនបើឆ្កែវាយប្រហារ គ្រវីអាវ កាបូប កង់ ឬ របស់អ្វីមួយដែលអ្នកអាចទុកចម្ងាយរវាងអ្នកនិងឆ្កែ។

-ប្រសិនបើឆ្កែ ឆ្មា ឬ សត្វចញ្ចឹមក្នុងផ្ទះខាំអ្នក ឬកូនរបស់អ្នក គួរចាប់សត្វទាំងនោះឃាំងទុករយៈពេល ១០ថ្ងៃ (ប្រសិនបើអះអាងថាមានសុខភាពល្អបន្ទាប់ពី១០ថ្ងៃ អ្នកនឹងប្រហែលជាមិនមានជម្ងឺឆ្កួតឡើយ)។

**-គ្រប់របួសដំបៅ** គួរតែលាងរបួសយ៉ាងម៉ត់ចត់ និងយកចិត្តទុកដាក់ប៉ុន្តែលាងជាមួយសាប៊ូ និងទឹកចំនួន ១៥នាទី។ (ប្រសិនបើអាចលាយទឹក baceria សម្លាប់ភ្នាក់ងារចម្លងរោគដូចជាសូលុយស្យុង povidine-iodine គួរប្រើដើម្បី បណ្តក់លើរបួសដំបៅ) បន្ទាប់ពីពិនិត្យដោយក្រុមគ្រូពេទ្យ ដើម្បីកំណត់ថា តើវ៉ាក់សាំងឆ្កែឆ្កួតចាំបាច់ឬយ៉ាងណា។

➢ **ការដក់បារីក្នុងបន្ទប់ :**

ជាតិដែលបណ្តាលឱ្យរលាកពីការជក់បារីក្នុងបន្ទប់នោះគឺជាការចូលរួមជាមួយរោគហឺត និងគឺជាលក្ខណៈបង្កសាមញ្ញមួយនៃការបំផ្លាញសួត។ នៅក្នុងលក្ខខណ្ឌ ជាតិពុលកាបូនម៉ូណូស៊ីត គឺបង្កឡើងដោយហ្គាសដែលមើលមិនឃើញដែលជារោគបង្កនៅពេលណា ដែលអាហារធ្យូង ឬ ឥន្ធនៈផូស៊ីលត្រូវបានគេដុតឡើង។ វាក៏ជារោគបង្កនៅពេលណាដែលឥន្ទនៈត្រូវបានគេដុតនៅក្នុងម៉ាស៊ីន។ ហ្គាសនេះគឺគ្មានពណ៌ និងគ្មានក្លិនដូច្នេះអ្នកមិនអាចមើល ឬ ហិតឃើញឡើយ។

វាគឺសាមញ្ញមួយនៅពេលដែលអាកាសធាតុត្រជាក់ និងការដុតឥន្ធនៈខាងក្នុងបន្ទប់ដោយគ្មានខ្យល់ចេញចូលគ្រប់គ្រាន់ ដូច្នេះជាតិពុលហ្គាសមិនអាចហុយចេញបានឡើយ។ ជួនកាលក្រុមគ្រួសារគឺស្វែងរកសេចក្តីស្លាប់។ មានជម្ងឺមុនគេនោះគឺរួមមាន ជម្ងឺឈឺក្បាល ក្អួតចង្អោរ និងជម្ងឺហត់។

**របៀបបង្ការមរណៈភាពពីជាតិពុលកាបូនម៉ូណូស៊ីត :** រមែងតែងតែប្រាកដប្រជាគឺចង្ក្រានរបស់អ្នកដែលជាមុនងារ ស័ក្តិសមបំផុត ឬក៏ទ្វារ ឬបង្អួចចំហរ។

## 47. ការជួយជាបន្ទាន់

➢ **ការគ្រេច ( ចូរមើលរូបភាព) :**

ចូរលើកជើងរបួសឡើង។ ការស្អំតឹកកកអាចនឹងជួយបាន ជាពិសេសក្នុងកំឡុងពេល៦ម៉ោងដំបូង។ ជូរស្វែងរកដំបូន្មាន ពីឱសថ (ថ្នាំពេទ្យ) បើសិនជាមានការឈឺចាប់ ឬ ឡើងហើម។ បើសិនជាគ្រេចបន្តិចបន្តួចៈ ចូរបន្តលើកជើងឱ្យមានកំពស់ ឈប់សំរាក និង រុំបង់របួស (រុំឱ្យតឹង)រយៈពេល២-៣ថ្ងៃ នោះនឹងមានសកម្មភាពត្រឡប់ដូចដើមវិញ។

➢ **ភ្នែក :**

ចូរព្យាយាមសំអាតរបស់ខាងក្រៅដោយថ្នមៗដោយប្រើសំលីត្បាល់ត្រចៀកដែលសំអាតហើយសើម។ ការឈឺចាប់នៅក្នុងភ្នែកមកពីរបស់ខាងក្រៅ ដុសចេញក្រម៉ និងខ្វាច(ឬ អេះ...។ល។) អាចធ្វើឱ្យធូរស្រាលដោយសារការរុំប៉ង់ស៊ីម៉ងរហូតដល់ថ្នាំបានជួយឱ្យជាសះស្បើយ។ សំរាប់ការសាច់ជាតិគីមីចូលភ្នែក លាងសំអាតជាមួយទឹកស្អាតនិងបន្តរយៈពេល ១៥នាទី។កុំប្រើប្រាស់ទឹកបន្តក់ ឬ ប្រេង ចូរស្វែងរកថ្នាំជំនួយ។

➢ **ឈាមច្រមុះ :**

ជានិច្ចកាលការហូរឈាម គឺមកពីប្រឈមមុខប៉ះតង្កិចខ្ទង់ច្រមុះ។ ចូរទៅនៅទីកន្លែងអង្គុយ ច្របាច់ខាងក្រៅរន្ធច្រមុះជាមយយនឹងមេដៃ និង ម្រាមដៃចអង្គុលទុករយៈពេល៥-១០នាទី និងមិនត្រូវឈប់កាន់ក្នុងរយៈពេ៉៥-១០នាទីនោះទេ។ ការហូរឈាមនៅក្នុងច្រមុះ គឺដូចជាការហូរឈាមនៅគ្រប់កន្លែងផ្សេងៗទៀតៈ បើសិនជាអ្នកកាន់បណ្តោះអាសន្ន អ្នកនឹងធ្វើឱ្យឈាមកក បែបនោះឈាមនឹងហូរម្តងទៀត។ (ជាញឹកញាប់ឈាមច្រមុះអាច នឹងទប់ទល់ដោយសារក្រចកដៃកាត់ឱ្យខ្លី នឹងដាក់នឹងប្រេងលាបស្បែក ជាច្រើនព្រោះថា វ៉ាសែលីន ប្រឈមមុននឹងការបែកពាក់កណ្តាលច្រមុះ)។

## 48. សង្គ្រោះជម្ងឺឈ្លក់ ៖ បំបុកពោះ (ហត្ថកម្ម Heimlich)

➢ **ការឈ្លក់ ៖**

មនុស្សមួយចំនួនដែលឈ្លក់អ្វីមួយ និងកំពុងតែក្អកនៅឡើយយំ ឬ អាចបង្កើតនូវសម្លេងនានាគឺជា LEFT ALONE ល្អបំផុតមួយ។ ការបំបុកពោះអាចបង្កការបំផ្លាញនូវសរីរាង្គខាងក្នុង ជាពិសេសនៅលើក្មេងៗ ដូច្នេះគួរតែប្រាកដប្រជានូវផ្លូវដង្ហើមគឺត្រូវបានបង្អាក់ទាំងស្រុង។ សួរទៅអ្នករងគ្រោះប្រសិនបើឈ្លក់។ (អ្នករងគ្រោះរមែងតែងតែ ដូចជាក្មេងនៅក្នុងរូបភាព ហើយនឹងយកដៃរបស់ពួកវាដាក់លើបំពង់ករ និងភ្នែកនឹងកាន់តែឈឺចាប់ខ្លាំង និងរកកលនិយាយមិនចេញ) ប្រសិនបើមនុស្សមិនអាចបញ្ចេញសំឡេងបាន និងគ្មានចលនាខ្យល់ ដូចនេះគួរតែបំបុកពោះជនរងគ្រោះ។

➢ **ការបំបុកពោះជាមួយនឹងការឈរ ឬ អង្គុយរបស់ជនរងគ្រោះដែលដឹងខ្លួន (មើលរូបភាព ផ្នែកខាងលើ) ៖**

១-ឈរខាងក្រោយជនរងគ្រោះ។ យកមេដៃនៃកណ្ដាប់ដៃប្រឆាំងនឹងពោះជនរងគ្រោះនៅជួរកណ្ដាលយ៉ាងតិចៗ ខាងលើផ្ចិត និងខាងក្រោមដើមទ្រូង។

២-កាន់កណ្ដាប់ដៃជាមួយដៃផ្សេង និងប្រើការបំបុក៥ដងយ៉ាងលឿនឡើងលើ។ កណ្ដាប់ដៃមិនគួរប៉ះផ្នែកខាងក្រោមនៃឆ្អឹងកងរបស់ឆ្អឹងជំនីដូចជាអាចបំផ្លាញសរីរាង្គខាងក្នុង។

៣-ការបំបុកនីមួយៗគួរតែបំបែកចលនាខុសៗគ្នា និងគួរតែបន្តរហូតដល់របស់ទាំងនោះត្រូវបានបណ្ដេញចេញ ឬ ជនរងគ្រោះសន្លប់។

➢ **ការបំបុកពោះជាមួយជនរងគ្រោះដឹងខ្លួន ឬ សន្លប់ផ្ដេកចុះ ( មើលរូបភាពខាងក្រោម) ៖**

១-ដាក់ជនរងគ្រោះនៅលើខ្នងរបស់គាត់ជាមួយក្បាលរបស់គាត់ទៅនឹងផ្នែកមួយ និងបើកខ្យល់ដង្ហើម។ លុតជង្គត់ជិតជនរងគ្រោះ ឬ កន្ទែកជើងត្រង់ត្រគៀករបស់គាត់។

២-ដាក់កែងជើងនៃដៃមួយនៅលើពោះជនរងគ្រោះនៅជួរកណ្ដាលយ៉ាងហ្មត់ចត់ខាងលើផ្ចិត និងបង្អួសខាងក្រោមដើមទ្រូង។ ដៃម្ខាងទៀតគួរតែលើកឡើងលើឱ្យខ្ពស់នៃជំហានដំបូង។

៣-ចុចដៃទាំងពីរទៅលើពោះជាមួយការបំបុកឡើងទៅលើ។ ប្រសិនបើចាំបាច់យកម្រាមទាំង៥បំបុក និងការបំបុកនីមួយៗគឺបំបុកឡើងលើផ្ទាល់នៅកណ្ដាលជួរ និងមិនគួរបំបុកផ្ទាល់ទៅនឹងផ្នែកណាមួយនៃពោះ។

៤-បន្ទាប់ពីទទួលបានការបំបុកពោះ៥លើករួចហើយ ព្យាយាមជួយឱ្យរួចពីគ្រោះថ្នាក់របស់ការដកដង្ហើម ៖ ប្រសិនបើ ផ្លូវដង្ហើមនៅតែស្ទះដង្ហើម បន្តហត្ថកិច្ចសារជាថ្មី។

## 49. ការស្តារឡើងវិញពីមហន្តរាយ និងព្រឹត្តិការណ៍ស្លាមរបួសផ្សេងៗ

យើងតែងតែបារម្ភចំពោះមនុស្សដែលបានរងគ្រោះពីសរីរៈ ឬ រំលោភបំពានផ្លូវភេទ ឬ ការរំលោភសេពសន្ថវៈលើស្ត្រី ឬ បានទទួលរងគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬ រងរបួសដោយសោកនាដកម្មសង្គ្រាម។ ផ្សេងពីនេះគឺគ្របដណ្តប់ដោយមហន្តរាយដូចជា ខ្យល់ព្យុះ និងរញ្ជួយដែនដី។ ព្រឹត្តិការណ៍ស្លាមរបួសទាំងឡាយនេះគឺតែងតែកើតឡើងភ្លាមៗ និងដែលលើសលុប។ ក្នុងករណីមួយចំនួន គ្មានសញ្ញាប្រាប់ឱ្យដឹងភ្លាមៗឡើយ ដូចជារងគ្រោះលើរាងកាយ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយការវាយដួងរណ្តើនចិត្តអោយដឹង។ ការក្រៀមក្រំ ទុក្ខព្រួយ សេចក្តីក្រោធ និងការរំជួលចិត្ត ជ្រៅទៅៗ គឺជាប្រតិកម្មធម្មតា។ ការយល់បែបនេះគឺជាការឆ្លើយតបធម្មតា ទៅនឹងព្រឹត្តិការណ៍របួសស្លាមអាចជួយអ្នកប្រសិទ្ធិភាពក្នុងការចម្លងជាមួយអារម្មណ៍របស់អ្នកការគិត និងឥរិយាបថផ្សេងៗ និងជួយអ្នកតាមផ្លូវដើម្បីសារឡើងវិញ។

**ខាងក្រោមនេះគឺជាការឆ្លើយតបធម្មតាមួយទៅនឹងគ្រោះមហន្តរាយ ឬ ក៏ព្រឹត្តិការណ៍ដែលធ្វើឱ្យស្លុតមុខងារមនសិការ**

អ្នកដែលបានទទួលរងការធ្វើឱ្យស្លុតអាចធ្វើអវិចារណៈភាព មានការបង្កើតការសម្រេចចិត្តផ្សេងៗគ្នា ឬ អាចជាសកម្មនៅក្នុងមធ្យោបាយដែលជាកាយវិការខុសឆ្ងាយសម្រាប់ពួកគេ។ ជាដំបូងអ្នកអាចមានអារម្មណ៍តក់ស្លុត (អារម្មណ៍ងឺងើ ភ្លឹក ឬ ភាំង ស្ពឹក ឬ រន្ធត់) ឬ ការបដិសេធ (មិនមានចំណេះដឹងពេញលេញឥតល្បើង)។ ការផ្លាស់ប្តូរការឆ្លើយតបបន្ទាប់ទៀតជាមួយព្រឹត្តិការណ៍ផ្សេងៗ។ អ្នកអាចមានបទពិសោធន៍ : ភាពឆាប់ខឹង ឬ សេចក្តីក្រោធ បន្ទោសខ្លួនឯង ឬ បន្ទោសអ្នកដទៃ អារម្មណ៍ឯកកោ និងនៅម្នាក់ឯង អារម្មណ៍ភ័យខ្លាចកើតឡើងផ្ទួនៗ អារម្មណ៍តេលតោល អារម្មណ៍វិលវល់ អារម្មណ៍កើតទុក្ខព្រួយ ក្រៀមក្រំក្នុងចិត្ត និង សេចក្តីសោកសៅ ឬ ការប្រមូលផ្តុំ និងបញ្ហាការ ចងចាំ។

- ### សុខភាពសាពាង្គកាយ :

ដំបៅស្រ្តេសអាចមានមូលហេតុមកពីជំងឺសរីរៈដែលអាចកើតរួមមាន : ការបាត់បង់ ចំណង់ ឈឺក្បាល ឬ តឹងទ្រូង រាគរាក ចុកពោះ ឬ ក្អួតចង្អោ ធ្វើការងារច្រើនហួសកំរិត សុបិនអាក្រក់ គ្មាន លទ្ធភាពនឹងដេក ឬ អស់កម្លាំង ឬ ខ្សោយថាមពល។

ទំនាក់ទំនងរវាងបុគ្គល : ទាំងអម្បាលនោះ ដែលជាការកើតមានដំបៅស្រ្តេស ហើយអាចទទួលរងការផ្លាស់ប្តូរបុគ្គលភាពបណ្តោះអាសន្ន ដែលអាចបង្កើតការទំនាក់ទំនងមនុស្សខាងក្រៅយ៉ាងពិបាក។ នោះអាចបង្កើនជំលោះជាមួយមិត្តភ័ក្តិ និងធ្វើការជាមួយ ឬ ទាស់ទែងរវាងប្តី និងប្រពន្ធ។ វាក៏សំខាន់ផងដែរដើម្បីយល់ថាគ្មានប្រតិកម្ម

“ ស្តង់ដា ” ទៅនឹងស្ត្រេសធ្ងន់ធ្ងរ និងយើងនឹងធ្វើការបកស្រាយខុសៗគ្នា។ មនុស្សមួយចំនួនប្រតិកម្មភ្លាមៗ និងស្តារឡើងវិញយ៉ាងរហ័ស ខណៈអ្នកដទៃទៀតបានពន្យាពេលនូវការបកស្រាយ។

## ➢ តើខ្ញុំអាចជួយគ្រួសាររបស់អ្នក និងជួយខ្លួនឯងដោយរបៀបណា ?

យើងត្រូវការខុសៗគ្នា និងមធ្យោបាយផ្សេងៗគ្នានៃការលៃលកដោះស្រាយ។ ផ្តោតលើការកម្លាំង និងសមត្ថភាព នឹងអាចជួយអ្នកដើម្បីភាពប្រសើរឡើងវិញ។ មួយលំដាប់ម្តងៗនឹងរកឃើញដើម្បីជួយ :

-ផ្តល់ពេលវេលាផ្ទាល់ខ្លួនដើម្បីទៅរកភាពប្រសើរឡើងវិញ។ ព្រមឱ្យខ្លួនអ្នកផ្ទាល់កាន់ទុក្ខនូវការបាត់បង់អ្វីមួយដែលអ្នកបានទទួលបទពិសោធន៍។ ព្យាយាមអត់ធ្មត់ជាមួយការផ្លាស់ប្តូរភាពរំជួលចិត្តរបស់អ្នក និងគ្រួសារ។

-យកចិត្តទុកដាក់លើឥរិយាបថសុខភាព ដើម្បីជួយអ្នកដោះស្រាយជាមួយនឹងកម្លាំងសរីរៈ (ស្ត្រេស) : បោះជំហានដើម្បីបង្កើនសាពាង្គកាយ និងធ្វើឱ្យប្រសើរឡើងខាងផ្លូវចិត្តដោយថែទាំសុខភាពរស់នៅ។ (ឧទាហរណ៍ សុខភាព ញ៉ាំអាហារ សំរាក លំហាត់ប្រាណ លំហែកាយ និងភាវនា)។

-ព្យាយាមស្វែងរកក្រុមគាំទ្រក្នុងស្រុកជាមួយនរណាម្នាក់ ដែលមានបទពិសោធន៍ស្រដៀងគ្នានឹងស្ត្រេស

-ស្នើសុំការជួយឧបត្ថម្ភពីក្រុមទាំងនោះដែលបារម្ភអំពី ទំនាក់ទំនងនឹងបទពិសោធន៍ទៅមធ្យោបាយណាមួយដែលមានអារម្មណ៍ថា មានផាសុខភាពចំពោះអ្នក ដូចជាការនិយាយស្តីទៅកាន់គ្រួសារ អ្នកគង្វាល ឬ មិត្តភ័ក្តិជិតស្និត ឬ រក្សានូវសៀវភៅកំណត់ហេតុប្រចាំថ្ងៃ។ ប្រើការភាវនា និង/ឬ ធនធានខាងផ្លូវចិត្តឯទៀត។

## ➢ ការសង្គ្រោះកុមារពីមហន្តរាយ :

មហន្តរាយអាចធ្វើឱ្យមានការភិតភ័យដល់ស្រទាប់យុវជន ប៉ុន្តែពួកគេមានដំបៅ សម្រាប់ក្មេងៗ ជាពិសេសប្រសិនបើពួកគេមិនដឹងថាធ្វើអ្វី។

-កុមារអាស្រ័យលើទំលាប់ប្រចាំថ្ងៃ។ នៅពេលគ្រោះអាសន្នកើតឡើងតែងកាត់ផ្តាច់ទំលាប់ ហើយកុមារតែងក្លាយជាអន្ទះសារ។ ការចាត់តាំងជាថ្មីនូវកាលវិភាគទូទៅសម្រាប់ញ៉ាំ លេង ការងារឱ្យចំណីសត្វ ការងារក្នុងផ្ទះ និងការចូលគេងនឹងជួយស្តារឡើងវិញនូវវិញ្ញាណសុវត្ថិភាព។

-នៅក្នុងមហន្តរាយពួកវានឹងសង្ឃឹមលើអ្នក និងក្មេងជំទង់ឯទៀត។ ទោះបីជាយ៉ាងណាក៏ដោយអ្នកមានប្រតិកម្មទៅនឹងគ្រោះអាសន្នដែលផ្តល់ជាសញ្ញានៅលើរបៀបធ្វើសកម្មភាព។ ប្រសិនបើអ្នកមានសកម្មភាពជាថ្មីនូវសញ្ញាព្រមាន ក្មេងៗអាចមានការភ័យខ្លាចច្រើន។ ពួកគេឃើញ ការភ័យខ្លាចពិតប្រាកដរបស់ពួក

យើងដែលជាគ្រោះថ្នាក់ពិតប្រាកដ។ ប្រសិនបើអ្នកខំប្រឹងជាមួយនឹងវិញ្ញាណបាត់បង់ ក្មេងៗអាចមានអារម្មណ៍ភ័យខ្លាចខ្លាំងជាងយើង។

-ក្មេងៗតែងតែថយកម្លាំង និងបង្ហាញអត្តចរិកក្មេងដូចជា ជញ្ជក់មេដៃ និងញ័រភ័យ។ ក្មេងៗភ័យខ្លាចស្ដែងចេញពីការគិតរវើរវាយ និងអ្នកគួរតែយកអារម្មណ៍ទាំងនេះធ្ងន់ធ្ងរ។

-អារម្មណ៍ភ័យខ្លាចគឺជាសុខភាព និងធម្មជាតិសម្រាប់យុវវ័យ និងកុមារ។ ប៉ុន្តែសំរាប់យុវវ័យ គួរតែចេះគ្រប់គ្រងស្ថានការណ៍ នៅពេលដែលប្រាកដថាគ្រោះថ្នាក់ឆ្លងផុត។

-ការចូលរួមរបស់កុមារនៅក្នុងសកម្មភាពសង្គ្រោះគ្រួសារនឹងជួយដល់ពួកគេមានអារម្មណ៍ថា ជីវិតរបស់ពួកគេទៅរកភាពដើមវិញ ហើយអ្វីដែលយើងឆ្លើយតបខណៈនេះប្រហែលអាចមានប៉ះទង្គិចបានយូរមួយ។

-ដើម្បីដឹងអំពីអ្វីមួយបន្ទាប់ពីមហន្តរាយ ក្មេងៗគឺមានការ**ភិតភ័យខ្លាំង** ថា : ព្រឹត្តិការណ៍នឹងកើតឡើងម្ដងទៀត ដូច្នេះ នរណាម្នាក់នឹងត្រូវរងគ្រោះ ឬ បាត់បង់ជីវិត ហើយពួកគេនឹងដើរចេញពីក្រុមគ្រួសារ ឬ ពួកគេនឹងចាកចេញនៅម្នាក់ឯង។

- **ភ្លាមៗបន្ទាប់ពីមហន្តរាយ ព្យាយាមកាត់បន្ថយភាពភ័យខ្លាចរបស់កុមារ និងការថប់អារម្មណ៍ :**

-ត្រូវថែរក្សាគ្រួសាររួមគ្នា។ ខណៈដែលអ្នកស្វែងរកលំនៅដ្ឋាន និងជាជំនួយការ នោះអ្នកប្រហែលជាចង់ចាកចេញពីកូនរបស់អ្នក ក្រុមគ្រួសារ និងមិត្តភ័ក្តិ។ រក្សាគ្រួសាររួមគ្នាឱ្យបានច្រើនដែលអាចធ្វើបាន និងធ្វើការថែរក្សាក្មេងៗឱ្យបានល្អ។

-ការពន្យល់នូវស្ថានភាពយ៉ាងទន់ភ្លន់ និងកក់ក្ដៅ។ ល្អដូចដែលអ្នកអាច ប្រាប់កូនរបស់អ្នកដែលអ្នកដឹងអំពីភយន្តរាយ។ ពន្យល់អ្វីដែលនឹងកើតឡើងបន្ទាប់។

-លើកទឹកចិត្តដល់កុមារឱ្យនិយាយអំពីព្រឹត្តិការណ៍ភ័យខ្លាច និងឱ្យពួកគេសួរសំណួរឱ្យបានច្រើននូវអ្វីមួយដែលគេចង់។ លើកទឹកចិត្តកុមារឱ្យពណ៌នាអំពីអារម្មណ៍របស់ពួកគេ។ ប្រសិនបើពួកគេក្មេងពេក ឱ្យពួកគេគូសរូបនូវអ្វីដែលបានកើតឡើង និងឱ្យពន្យល់ដល់យើង។ ស្ដាប់នូវអ្វីដែលពួកគេនិយាយ។ ប្រសិនបើអាចរួមទាំងក្រុមគ្រួសារទាំងអស់ នៅក្នុងកិច្ចពិភាក្សា។

-រួមទាំងកូនរបស់អ្នកនៅក្នុងសកម្មភាពដូចដើមវិញ។ ផ្ដល់ឱ្យកុមារធ្វើការងារដែលជាការទទួលខុសត្រូវ។ ទាំងនេះនឹងជួយបង្កើតអារម្មណ៍របស់កុមារដែលជាផ្នែកមួយនៃស្ថានភាពដើម។ មានកិច្ចការមួយនឹងជួយឱ្យពួកគេយល់ថា អ្វីៗនឹងត្រឹមត្រូវទាំងអស់។

➢ **គ្រួសារមានផែនការបន្ទាន់ :**

គ្រប់ៗគ្នានៅក្នុងផ្ទះសម្បែងរួមទាំងកុមារ គួរតែមានទំនួលខុសត្រូវគ្រួសារ និងខិតខំស្តារឡើងវិញ។

-បង្រៀនកូនរបស់អ្នកពីរបៀបរៀបចំសញ្ញាណគ្រោះថ្នាក់។ ប្រាកដថាកូនរបស់អ្នកដឹងពីធ្វីដែលជាសញ្ញានៃអគ្គីភ័យ និងប្រព័ន្ធប្រកាសអាសន្នក្នុងសហគមន៍ (ស៊ីផ្លេ ឬស៊ីរ៉ែន)។

-បង្រៀនកូនរបស់អ្នកពីរបៀបហៅទូរស័ព្ទសម្រាប់រកជំនួយពេលជួបគ្រោះអាសន្ន។ ព្យាយាមឱ្យកូនរបស់អ្នកចងចាំពី ឈ្មោះគ្រួសារ អាស័យដ្ឋាន លេខទូរស័ព្ទប្រើក្នុងផ្ទះ និងតំបន់។ ពួកគេគួរតែដឹងផងដែរពីកន្លែងជួប ក្នុងករណីបន្ទាន់។

## 50.សេចក្តីសរុប — ចំណេះដឹងសំខាន់បន្ថែម (សង្ខេប)

ដូចនេះចំណេះដឹងសំខាន់ពីប្រភពដ៏ល្អបំផុតដែលយើងអាចស្វែងរកនៅលើពិភពលោក។ គឺបានមកពីអង្គការសុខភាពពិភពលោក និង ដៃគូសហការប្រមូលឯកសារដែលរួមទាំងគ្រូពេទ្យដ៏ល្អ និង អ្នកឯកទេសខាងសុខភាពពីជុំវិញពិភពលោក។ គឺវាមានសារៈសំខាន់បំផុតដែលនឹងជួយអ្នកអាចសង្គ្រោះជីវិតជាច្រើន និង ការពារនូវសេចក្តីរងទុក្ខទៅអ្នកគ្រួសារអ្នក និង សហគមន៍របស់អ្នក។

សារៈសំខាន់នៃសេចក្តីស្រឡាញ់ទៅអ្នកដទៃត្រូវបានសង្កត់ធ្ងន់ដោយបុព្វជន (របស់អ្នក និង របស់ខ្ញុំ) និង រំឭកសារជាថ្មី ត្រង់ការចាប់ផ្តើមនៃកម្មវិធី (Section 2)។ សម្រាប់អ្នកជំងឺភាគច្រើនរបស់យើងដែលនៅមិនទាន់មានចំណេះដឹងផ្នែកសុខភាព។ របាយការណ៍របស់អង្គការសុខភាពពិភពលោកអះអាងបន្ថែមថា ប្រសិនបើយើងគ្រប់គ្នាអាចធ្វើការព្យាបាលទៅអ្នកដទៃនៅក្នុងលក្ខណៈមេត្តាករុណាពិតប្រាកដ នោះយើងនឹងបំបាត់អត្រាស្លាប់ និង សេចក្តីឈឺចាប់នៅលើសកលលោក យើងនេះ។

➢ **ជំហាន១០យ៉ាងគួរធ្វើ :**

- ការពាររោគអេដស៍ រួមដំណេក (រួមរ័ក) ជាមួយតែគូរស្វាមី និង ភរិយា ស្មោះត្រង់មួយនឹងមួយ។
- កុំជក់ និងកុំផឹកស្រា
- ថែរក្សា និង សម្អាតផ្ទះ និង បរិវេណជុំវិញផ្ទះឱ្យស្អាត និង កុំឱ្យមានមូស និង ធូលី។
- ញ៉ាំទឹកចំរុះ (ទឹកបរិសុទ្ធ)
- បំបៅទឹកដោះដល់កូន
- ប្រើ និង កសាងបង្គន់អនាម័យត្រឹមត្រូវ

- បង្រៀនកូនរបស់អ្នកអំពីអនាម័យក្នុងការរស់នៅដោយប្រើសាប៊ូលាងដៃ និង រំឭកឱ្យធ្វើដោយខ្លួនឯង (ក្មេងៗ)។
- ប្រុងប្រយ័ត្នក្នុងការប្រើប្រាស់ថ្នាំ សូម្បីតែថ្នាំរុក្ខជាតិក្តី
- ទុកថ្នាំឱ្យផុតពីដៃក្មេង
- និងចងចាំថាការព្យាបាលត្រូវមានការពិគ្រោះដោយគ្រូពេទ្យ គឺក្រុមស្រឡាញ់ការថែរក្សាសុខភាព។

## ➢ តើអ្នកមានសំណួរអ្វីបន្ថែម ដែរឬទេ?

អរគុណម្តងទៀតនូវសណ្តានចិត្តរបស់ក្រុមគ្រូពេទ្យព្យាបាលដោយឥតគិតថ្លៃ និង អរគុណសម្រាប់ការអញ្ជើញពួកយើងទៅសហគមន៍របស់អ្នក។ នៅពេលដែលពួកយើងចាកចេញ ពួកយើងនឹងធ្វើការចម្លងកម្មវិធីអប់រំសុខភាពនេះជាមួយ ________។ ក្តីសង្ឃឹមរបស់ពួកយើងថានឹងមានការជួបជុំសហគមន៍ ដើម្បីពិភាក្សាបន្ថែមនូវគោលការណ៍ណែនាំរបស់ WHO ដែលយើងបានរំឭកឡើងវិញ។ – និងអ្វីដែលអ្នកបញ្ជាក់បង្ហាញ និង ចាប់ផ្តើមស្វែងរកដំណោះស្រាយទៅនឹងបញ្ហានានា ដែលមានភាពចាំបាច់ទៅអ្នក និង សហគមន៍របស់អ្នក។

## ☺ ឯកសារយោង

មាតិការកម្មវិធីអប់រំសុខភាពសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ “Health Education Program for Developing Countries” គឺជានិច្ចកាលមានមូលដ្ឋានគ្រឹះ ប្រភពភ័ស្តុតាងគ្រោងដែលល្អបំផុត។ ប្រភពនេះសម្រាប់ព័ត៌មានភស្តុតាងគោល មានការផ្លាស់ប្តូរជាច្រើនឆ្នាំ។ មាតិការកម្មវិធីនេះគឺអាស្រ័យលើព័ត៌មានទាំងស្រុងជាច្រើន និង គោលការណ៍ណែនាំដែលមានស្រាប់តាមរយៈអង្គការសុខភាពពិភពលោក (WHO) និង ដៃគូប្រមូលឯកសារមានចំនួនច្រើនជាង ៩00។ គេហទំព័រ WHO គឺតែងតែបញ្ចូល ទិន្នន័យថ្មី (Update) ដើម្បីចូលរួមការផ្លាស់ប្តូរនៅក្នុងគោលការណ៍ណែនាំនៃភស្តុតាងគោល.

យើងមានការលុបទំព័រឯកសារយោងចាស់ៗចោល។

**សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រ** www.who.int

**សូមទំនាក់ទំនងកិច្ចការងារនេះជាមួយ :** Pat Van Winkle : pat@miracleofadoption.org

**៙៙៙ចប់៚៚៚**